ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង

អំពើជួញដូរមនុស្ស

លេខ ០៣៥/២២ គ.ជ.ប.ជ

# របាយការណ៍ត្រីមាសទី៤

# ស្តីពី

# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្ត ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ១.១.១. ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ កោះកុង ព្រៃវែង ក្រចេះ ស្វាយរៀង កំពត តាកែវ សៀមរាប បានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២១ ក្រោមប្រធានបទ "សូមកុំយកកូវីដ ១៩ ធ្វើជាឱកាសប្រព្រឹត្តអំពើជួញដូរមនុស្ស" និងផលិត សម្ភារ កម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ ហ្វេសប៊ុក សម្រាប់អបអរក្នុងយុទ្ធនាការ ដែលមានការចូលរួមពីថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ តាមរយៈការចែកខិត្តប័ណ្ណ ចងបដាពាក្យស្លោកពាក់ព័ន្ធនឹងការជួញដូរមនុស្សតាមសាលាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ តាមសាលារៀន និងនៅ

តាមទីសាធារណៈមួយចំនួនទៀត ដែលមានមនុស្សចូលរួមសរុបប្រមាណ៣៦១.៨៩៥នាក់ (ស្រី ១១០.៩៥៣នាក់)។ ដោយឡែកខេត្តព្រះវិហារ ត្បូងឃ្មុំ កំពង់ចាម ប៉ៃលិន និងខេត្តមួយចំនួនទៀត មិនបានរៀបចំជាមិទ្ទិញទេ តែបានផ្សព្វផ្សាយតាមរយៈបដា ពាក្យស្លោក នៅតាមទីសាធារណៈ និង ផ្សព្វផ្សាយបទយកការណ៍ដែលសហការផលិតដោយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងទូរទស្សន៍ បាយ័ន ឬធ្វើបទសម្ភាសន៍ នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់ខេត្ត សរុបចំនួន ២៣បដា និងពាក្យស្លោក ៤៦ផ្ទាំង។

### ១.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **អគ្គលេខាធិការដ្ឋាន** នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ដោយមាន កិច្ចសហការបច្ចេកទេសពីក្រសួងសុខាភិបាល និងទទួលបានការគាំទ្រពីអង្គការយូនីសេហ្វ៖
  - បានរៀបចំកម្មវិធីផ្សព្វផ្សាយ ស្តីពី "**ក្រមសីលធម៌មន្ត្រី នៅមណ្ឌលចត្តាឡីស័ក និងសេវាគាំទ្រ**" តាម ប្រព័ន្ធ Zoom ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងមានការចូលរួមពី ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការយូនីសេហ្វ អង្គការ TPO ព្រមទាំងសមាសភាព ពាក់ព័ន្ធ ពីបណ្តាខេត្តគោលដៅ មានអ្នកចូលរួមសរុបប្រមាណ ២០០នាក់។
  - បានរៀបចំកម្មវិធីផ្សព្វផ្សាយ តាមប្រព័ន្ធ Zoom ស្តីពី "**ក្រមសីលធម៌មន្ត្រីនៅមណ្ឌលចត្តាឡីស័ក និង សេវាគាំទ្រ**" ក្រោមអធិបតីភាព លោកជំទាវ **វ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ និងមាន ការចូលរួម ពីអង្គការ TPO ព្រមទាំងសមាសភាពពាក់ព័ន្ធ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្ត ត្បូងឃ្មុំ មានអ្នកចូលរួមសរុបប្រមាណ ៣០០នាក់។
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បាន៖** ១-សហការជាមួយនិយ័តករ ទូរគមនាគមន៍កម្ពុជា(TRC) នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជំរុញប្រតិបត្តិករផ្នែកសេវាកម្ម ទូរគមនាគមន៍ ធ្វើការផ្ញើសារ(SMS)ផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ នៅថ្ងៃទិវាជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ១២ធ្នូ ដែលមានខ្លឹមសារថា "**សូមកុំយកកូវីដ ១៩ ជាឱកាសប្រព្រឹត្តអំពើជួញដូរ មនុស្ស**")។ ២-ផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធ ស្តីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈផេកហ្វេសប៊ុក ដែលមានអ្នកទស្សនា សរុបចំនួន ២៤.១២០នាក់។
- **ខេត្តព្រៃវែង៖** រដ្ឋបាលស្រុកបាភ្នំ សហការជាមួយក្រសួងកិច្ចការនារី រៀបចំវេទិកាផ្សព្វផ្សាយ ស្តីពី សកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់អំពើជួញដូរស្ត្រី និងកុមារ និងរាល់ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗ ចំនួន ០១លើក អ្នកចូលរួមចំនួន ៤២នាក់ (ស្រី ៣២នាក់)។
- **ខេត្តក្រចេះ៖** មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចុះផ្សព្វផ្សាយអំពីការកេង ប្រវ័ញ្ចលើពលកម្មកុមារ ការទប់ស្កាត់រាល់សកម្មភាពជួញដូរ និងប្រើអំពើហិង្សាលើបុគ្គលិក កម្មករ (ពិសេសកុមារ) តាមបណ្តាស្ថានីយ៍ប្រេងឥន្ធនៈ នៅក្នុងស្រុកស្នួល និងក្រុងក្រចេះ បានចំនួន០៨ មូលដ្ឋាន មានបុគ្គលិក ១៨នាក់ (ស្រី ០៨នាក់)។
- **ខេត្តកំពង់ស្ពឺ៖** មន្ទីរកិច្ចការនារីខេត្ត បានចុះផ្សព្វផ្សាយអប់រំតាមខ្នងផ្ទះ និងក្រុមតូចៗ ចំនួន ០៣លើក អំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងការជួញដូរស្ត្រី និងក្មេងស្រី នៅ ស្រុក ថាឡាបរិវ៉ាត់ និងស្រុកបូរីអូរស្វាយសែនជ័យ អ្នកចូលរួមចំនួន ១៦៦នាក់ (ស្រី ១២៦នាក់)។

- **ខេត្តរតនគិរី៖** មន្ទីរអប់រំ យុវជន និងកីឡា បានប្រជុំតាមប្រព័ន្ធ Zoom ជាមួយយុវជន កុមារ និងសាលាចំនួន២៥ ក្នុងខេត្តរតនគិរី ដើម្បីផ្សព្វផ្សាយអំពីការរំលោភបំពាននានាលើកុមារ ការជួញដូរកុមារ និងការប្រើប្រាស់គ្រឿងញៀន សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ សរុប ៩០៩នាក់ (ស្រី ៤៥២នាក់)។
- **ខេត្តសៀមរាប៖**
  - **មន្ទីរកិច្ចការនារីខេត្ត** បានរៀបចំវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ផ្សព្វផ្សាយអំពីតួនាទីភារកិច្ចភ្នាក់ងារនគរបាលយុត្តិធម៌ របស់មន្ទីរ និងកិច្ចអន្តរគមន៍ ក្នុងការផ្តល់សេវាជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការលុបបំបាត់ រាល់ទម្រង់រើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ) និងការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ស្រុកក្រឡាញ់ សូទ្រនិគម ស្រុកប្រាសាទបាគង ស្រុកវ៉ារិន ស្រុកបន្ទាយស្រី ស្រុកស្វាយលើ និងស្រុកពួក បាន ១១លើក អ្នកចូលរួមចំនួន ១.៧០៥នាក់ (ស្រី ១.០០៨នាក់)។
  - **រដ្ឋបាលស្រុកស្រីស្នំ ៖** សហការជាមួយអង្គការ IOM រៀបចំទិវាអន្តរជាតិជនទេសន្តរប្រវេសន៍ ១៨ធ្នូ ដើម្បីលើកកម្ពស់ការយល់ដឹងអំពី ទិវាអន្តរជាតិជនទេសន្តរប្រវេសន៍ និងសារសំខាន់នៃការរួមចំណែករបស់ពលករទេសន្តរប្រវេសន៍នៅក្នុងសង្គម បាន ០១លើក អ្នកចូលរួមចំនួន ៨៨នាក់ (ស្រី៣០នាក់)។
  - **រដ្ឋបាលស្រុកចំនួន៤** (ស្រីស្នំ ក្រឡាញ់ ជីក្រែង ស្វាយលើ) សហការជាមួយអង្គការទេសន្តរប្រវេសន៍ (IOM) បើកវគ្គអប់រំផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការជ្រើសរើសពលករចូលរៀនជំនាញវិជ្ជាជីវៈ បាន ១០លើក អ្នកចូលរួមចំនួន ៤១៩នាក់ (ស្រី២២១នាក់)។
- **ខេត្តមណ្ឌលគិរី៖**
  - បានធ្វើការបញ្ជ្រាបការផ្សព្វផ្សាយច្បាប់ ស្តីពីទប់ស្កាត់អំពើរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ តាមរយៈជនបង្គោលយេនឌ័រ នៅក្នុងកិច្ចប្រជុំ គ.ក.ស.ក ក្រុង ស្រុក និងឃុំ សង្កាត់។
  - ជំរុញ និងបញ្ជ្រាបតាមសាលារៀន វត្តអារាម ព្រះវិហារ សូរ៉ាវ ស្នាក់ការថ្វាយបង្គំ និងអង្គការសមាគមមានចរិតសាសនា ក្នុងខេត្តមណ្ឌលគិរី ស្តីពីការទប់ស្កាត់ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងប្រើប្រាស់ពលកម្មកុមារ។

### ខ.១.៣. ការអប់រំដោយផ្ទាល់

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២១នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ២៤.១០៩លើក មានអ្នកចូលរួមសរុបចំនួន ១.១៥១.៧២៣នាក់ (ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២១ មានចំនួន ១.៧០១.៦៤៦នាក់ គឺមានការកើនឡើងចំនួន ៥៤៩.៩២៣នាក់ ស្មើនឹង៤៧,៧៤% ក្នុងនោះស្ត្រីចំនួន ៦១៥.៤៥១នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៧០ | ៤១៩៦ | ២១២៩ | | | |
| សរុប ក្រសួង ស្ថាប័ន | | ១៧០លើក | ៤.១៩៦នាក់ | ២.១២៩នាក់ | | | |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ១.២៣៨ | ៤៥.៣០៣ | ២០.៤៣៥ | ១.៩៦៨ | ១៥៣.០៨៣ | ៧៧.៦៧០ |
| ៣ | ខេត្តបាត់ដំបង | ២.៣០៧ | ៧៦.៤៣៧ | ៤២.០១៨ | ១.៥៥៤ | ៤១.១៣៨ | ២២.៩១៩ |
| ៤ | ខេត្តពោធិ៍សាត់ | ៧៤០ | ២៨.១៥៤ | ១៤.៦១៣ | ១២៦ | ៣.៩៧០ | ១.៧៣០ |
| ៥ | ខេត្តសៀមរាប | ១៧៧ | ៦.៦៨១ | ៣.៨៥៤ | ១៥ | ៣៨៩ | ១៩៥ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៣.៧២៨ | ៨៧.៦២៣ | ៦១.៣១០ | ១.៨៧០ | ៣៦.៦៤៤ | ១៩.១៧៤ |
| ៧ | ខេត្តកំពង់ចាម | ៤.៤៥០ | ៣៨៤.៩០០ | ២០០.៣៥៦ | ៣.០៨៩ | ១៨២.៨២២ | ១០២.០៣៣ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ២៨ | ៤.៥៧៩ | ២.៥៥៣ | ១០ | ២៤៤ | ១៥៩ |
| ១០ | ខេត្តស្វាយរៀង | ១ | ១១ | ៥ | ៧៣០ | ២០.៩៣២ | ១១.៣១៣ |
| ១១ | ខេត្តប៉ៃលិន | ២៩៨ | ៥.៧៨២ | ៣.២៩០ | ១៤៦ | ៤.៩៣០ | ២.៨៣៣ |
| ១២ | ខេត្តកោះកុង | ៤៤ | ៨៩៣ | ៤២២ | ៣៧ | ៦៦០ | ៣៣០ |
| ១៣ | ខេត្តកំពត | ៥៧ | ៧.០១២ | ១៤៣ | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ៦៩៩ | ១៩.២៦៦ | ៨.៨២២ | ៣០១ | ៧.៩៦៤ | ៣.៦៤៩ |
| ១៦ | ខេត្តក្រចេះ | ១៥៤ | ២០.៦៦១ | ១០.៥៦១ | | | |
| ១៧ | ខេត្តកែប | ២១ | ១.៩៦០ | ៧៩៦ | ៣០ | ៨៩១ | ៤០៦ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៧ | ៧៤៦ | ៣៣៨ | ៣២ | ១.០០៦ | ៤៥៤ |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ២ | ៤៩២ | ១៩៤ | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៥ | ១.៤៣០ | ៣៩៧ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ៧៥ | ៩២៤ | ៣៥០ | | | |
| សរុប រាជធានី-ខេត្ត | | ១៤.០៣១លើក | ៦៩២.៨៥៤នាក់ | ៣៧០.៤៥៧នាក់ | ៩.៩០៨លើក | ៤៥៤.៦៧៣នាក់ | ២៤២.៨៦៥នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ២៤.១០៩ នាក់ | | ចំនួនមនុស្សសរុប ១.១៥១.៧២៣ នាក់ | | ចំនួនស្ត្រី ៦១៥.៤៥១ នាក់ | |

### ខ.១.៤. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- ក្រុមជំនួយកិច្ចបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមរយៈផេកហ្វេកប៊ុក មានអ្នកចូលមើលចំនួន ៣២.១៦៦នាក់។

- ខេត្តសៀមរាប៖
  - មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM103MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ចំនួន ១៣៨លើក (ផ្សាយផ្ទាល់ ៥៦លើក និងចាក់ផ្សាយឡើងវិញ ៨២លើក)។
  - អង្គការមូលនិធិអេ២១ បានធ្វើការផ្សព្វផ្សាយ ស្តីពីសេវាផ្លូវច្បាប់ជូនដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សតាមបណ្តាញសង្គម និងវិទ្យុ ចំនួន ០១លើក អ្នកចូលមើលចំនួន ២.០០០នាក់។
- **ខេត្តកំពង់ឆ្នាំង៖** មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនិងការជួញដូរមនុស្សតាមរយៈការប្រជុំតាមប្រព័ន្ធ Telegram ឬ Google Meet ទៅដល់លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុកទាំង៨ ដើម្បីផ្សព្វផ្សាយបន្តទៅដល់ នាយក នាយិកា តាមសាលារៀននានា។
- **ខេត្តតាកែវ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈវិទ្យុគោកធ្លក និងទូរទស្សន៍គោកធ្លកសរុបចំនួន ១.៤០០លើក ក្នុងនោះផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពពាក់ព័ន្ធ និងអំពើជួញដូរមនុស្ស បានចំនួន ១៤លើក សារអប់រំខ្លីៗស្តីពីអំពីសកម្មភាពពាក់ព័ន្ធនិងអំពើជួញដូរមនុស្សបញ្ជ្រាបនៅចុងម៉ោង នៃកម្មវិធី បានចំនួន ៤៣៨លើក ផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដោយអំពើរជួញដូរ និងការធ្វើជីវកម្ម បានចំនួន ៦០លើក និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការប្រើប្រាស់គ្រឿងញៀង បានចំនួន ៩១៨លើក។
- **ខេត្តព្រះវិហារ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការទប់ស្កាត់ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងផ្សព្វផ្សាយទិវាជាតិ ១២ធ្នូ ឆ្នាំ ២០២១ តាមរយៈវិទ្យុ ទូរទស្សន៍ ហ្វេសប៊ុកផេក សរុប ៥២លើក។
- **ខេត្តត្បូងឃ្មុំ៖** បានចាក់ផ្សាយបទយកការណ៍ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ ២០២១ ក្រោមបទជានបទ "**សូមកុំយកកូវីដ-១៩ ជាឱកាសប្រព្រឹត្តអំពើជួញដូរមនុស្ស**" តាមទូរទស្សន៍ និងវិទ្យុជាតិត្បូងឃ្មុំ ដោយចាក់ផ្សាយក្នុងមួយថ្ងៃ ០៣លើក សរុបរួម ៦០លើក។
- **ខេត្តស្វាយរៀង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាអង្គការបេសកម្មអន្តរជាតិ IJM បង្កើតផ្សព្វផ្សាយកម្មវិធីវេទិកាតុមូល ក្រោមប្រធានបទ "**យើងរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ ពិសេសស្ត្រី និងកុមារ**" នៅវិទ្យុជាតិរំដួលស្វាយរៀង FM98.70MHz ០១លើក។

**ខ.១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចូលរួមជាវាគ្មិនទូរទស្សន៍ចំនួន ០១លើក "**យុទ្ធនាការរួមគ្នាបញ្ឈប់ការជួញដូរមនុស្ស ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១**" ដោយបានផ្តល់បទសម្ភាសន៍ពាក់ព័ន្ធនឹងការងារ និងច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ទូរទស្សន៍ BTV។
- ខេត្តកំពង់ចាម៖
  - មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានចូលរួមជាវាគ្មិនសន្ទនាមតិ ដើម្បីផ្សព្វផ្សាយ តាមរយៈវិទ្យុជាតិនៃមន្ទីរព័ត៌មានខេត្ត លើប្រធានបទ "**ការទប់ស្កាត់ការរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ**"។
  - ក្រុមការងារជំនាញនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ ដើម្បីផ្សព្វផ្សាយ តាមរយៈវិទ្យុ ០១លើក នៅវិទ្យុជាតិ នៃមន្ទីរពត៌មានខេត្ត និងព្រមទាំងផ្សព្វផ្សាយតាមបណ្តាញសង្គមហ្វេសប៊ុកផងដែរ។

- ខេត្តស្ទឹងត្រែង៖ ស្នងការដ្ឋាននគរបាលខេត្ត បានចាត់មន្ត្រីជំនាញ ០១រូប ចូលរួមជាវាគ្មិន ស្តីពីការរំលោភបំពានលើកុមារ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅស្ថានីយទូរទស្សន៍ ខេត្តស្ទឹងត្រែង ០១លើក។

## ខ.២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- ខេត្តបន្ទាយមានជ័យ
  - អង្គការសាម៉ារីតាន់ភីស ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន ២.៥០២នាក់ (ស្ត្រី ៨៩០នាក់) កុមារ ១៥២នាក់ (កុមារី ១០២នាក់)។
  - អង្គការ IOM៖ ចែកសៀវភៅ និងលេខទូរស័ព្ទ របស់មជ្ឈមណ្ឌលផ្តល់ព័ត៌មានចំណាកស្រុកដោយសុវត្ថិភាព ស្តីពីការធ្វើដំណើររបស់អ្នកប្រកបដោយសុវត្ថិភាព ១.១៦៧នាក់ (ស្រី៤៣៨នាក់)។
- ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភីស
  - បានចុះផ្សព្វផ្សាយតាមឧបករណ៍បំពងសម្លេង ឬមេក្រូពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរថយន្ត ម៉ូតូ បោះតង់ និងចែកខិតប័ណ្ណជូនដល់ប្រជាពលរដ្ឋ ចំនួន ២.២០០នាក់ (ស្រី ១.១២២នាក់)។
  - បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំនួន ១.២៤៨នាក់ (ស្ត្រី ៤៧៥នាក់) កុមារ ១០៨នាក់ (កុមារី ៤៣នាក់)។
- ខេត្តកំពង់ចាម៖ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត បានចុះផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធទៅនឹងវិស័យភាពយន្តដល់ម្ចាស់អាជីវកម្មលក់ VCD CD DVD ដើម្បីត្រួតពិនិត្យ VCD DVD ណាដែលមានរូបភាពអាសអាភាស និងបានធ្វើការហាមឃាត់ដល់ម្ចាស់អាជីវកម្មធ្វើសារាចរចូលទៅលើទីផ្សារ។

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.៣.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងជាប់ការទាក់ទង ប្រចាំខែនីមួយៗ បានពិនិត្យឃើញថានៅតែបន្តកើតមាន ជាក់ស្តែងក្នុងត្រីមាសទី៤ ឆ្នាំ២០២១នេះ តួលេខមានដូចក្នុងតារាងខាងក្រោម៖

| ប្រចាំខែ | ស្របច្បាប់ | | | មិនស្របច្បាប់ | | | ជាប់ការទាក់ទង | | |
|---|---|---|---|---|---|---|---|---|---|
| | ចំនួនរួម | ស្រី | អនីតិជន | ចំនួនរួម | ស្រី | អនីតិជន | ចំនួនរួម | ស្រី | អនីតិជន |
| តុលា | ៩៥.៣០៦ | ៤២.៦១៣ | ៣៥៦ | ៥៣.៧០១ | ២២.៨០៨ | ១.៤១៣ | ១១៣ | ៣១ | ០៦ |
| វិច្ឆិកា | ១៦៥.៣៧៥ | ៧៣.៨០៨ | ១.៣៨០ | ៧៧.៨៤៨ | ៣៣.៦១៨ | ២.៥៣០ | ២០៣ | ៦៩ | ០៣ |
| ធ្នូ | ១៦៦.១៧៤ | ៧៤.៨៣៨ | ១.៣៤៥ | ៧៧.៣៤៦ | ៣៣.១១៣ | ២.៥០០ | ១៧៦ | ៥៥ | ០១ |

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ចំនួន ៨២លើក មនុស្សចំនួន ១.០៨៩នាក់ (ស្រី ៤៥០នាក់) អនីតិជន ៣៣នាក់ និងបានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត។
- កម្លាំងជំនាញវរៈនគរបាលការពារព្រំដែនគោក ខេត្តបាត់ដំបង វរៈសេនាតូចលេខ៨១៧, ៨១៩ និង ៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន ៨៧លើក បានទប់ស្កាត់ពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ៧.៥៩៣នាក់(ស្រី ២៧៩នាក់) អនីតិជន ១០៦នាក់ រួចធ្វើការអប់រំ និងឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ។

### ខ.៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ព្រៃវែង ក្រចេះ និងខេត្តរតនគិរី ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ២០លើក។
  - ស្នងការដ្ឋាននគរបាលខេត្តតាកែវ ក្រចេះ កែប និងខេត្តព្រះសីហនុ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់ជាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា ជាប្រចាំក្នុងនោះ៖
    - ✓ ខែតុលា ចំនួន ៩២គោលដៅ មនុស្សចំនួន ២១៦នាក់ (ស្រី ១៤៨នាក់)
    - ✓ ខែវិច្ឆិកា ចំនួន ៦៩គោលដៅ មនុស្សចំនួន ១១៣នាក់ (ស្រី១០៨នាក់)
    - ✓ ខែធ្នូ ចំនួន២១៣គោលដៅ មនុស្សចំនួន ៥៨៣នាក់ (ស្រី៤៩០នាក់)។

### ខ.៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ១៦៦គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ និងបានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងចំនួន ២០នាក់។

## ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ខេត្តប៉ៃលិន៖** បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សេឡូ កាស៊ីណូ ឡូតដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៨០កន្លែង ជាលទ្ធផលរកពុំឃើញមានជួញដូរកម្លាំងពលកម្មកុមារទេ។
- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះទៅណែនាំផ្សព្វផ្សាយករណីការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារនៅតាមឡូតដ្ឋ ក្នុងនោះមានកុមារចំនួន ២០០នាក់ ហើយមន្ទីរបានឱ្យថៅកែធ្វើកិច្ចសន្យា។
- **ខេត្តក្រចេះ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារ នៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ខេត្តក្រចេះ ចំនួន ០២លើក ជាលទ្ធផលឃើញថា ការថែទាំ និងការឧបត្ថម្ភដល់កុមារ បានដំណើរការល្អប្រសើរ។
- **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះតាមដានត្រួតពិនិត្យ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅតាមសិប្បកម្មផលិតឥដ្ឋ បានចំនួន ០៣លើក ស្មើនឹង ០៩សិប្បកម្ម នៅស្រុកបន្ទាយស្រី ស្រុកអង្គរធំ និងស្រុកក្រឡាញ់ ជាលទ្ធផលពុំមានការប្រើប្រាស់ពលកម្មកុមារទេ។
- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញដែលបានដាក់ចំនួន ១.២២៧នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ៩០ករណី(ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២១ មានចំនួន ៧១ករណី កើនឡើងចំនួន ១៩ករណី) ស្មើនឹង ២១,១១% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១៣៤នាក់ (ស្រី ១៧នាក) អនីតិជន ១៤នាក់ ត្រូវបានចាប់ខ្លួន។ ក្នុងនោះជនសង្ស័យដែលជាជនបរទេសចំនួន ០៧នាក់ សញ្ជាតិចិន ០៥នាក់ និងសញ្ជាតិបង់ក្លាដេស ០២នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ៥៥១នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ៧៤នាក់ អាយុ១៥-១៧ឆ្នាំ ៦៣នាក់ និងអាយុពី១៨ឆ្នាំឡើង ៤១៤នាក់ (ប្រគល់ឱ្យគ្រួសារ ៥៥១នាក់) ក្នុងនោះចែកជាៈ

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ៥៧ករណី/ ៣៩ករណី (កើនឡើង ១៨ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៩៥នាក់ (ស្រី ១២នាក់) អនីតិជន ០៤នាក់ និងជនបរទេសសញ្ជាតិចិន ០៣នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៤៩៥នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ៥១នាក់ អាយុ១៥-១៧ឆ្នាំ ៤៥នាក់ និងអាយុ១៨ឆ្នាំឡើង ៣៩៩នាក់ (ប្រគល់ឱ្យគ្រួសារ ៤៩៥នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០១ | ០២<br>អនី.០២ | ចិន៣ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ៤៣ | ៣៩៧ | ៧៤<br>អនី.០២ | |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ១២ | ៩៦ | ១៦ | |
| -ការទិញពេស្យាចារកុមារ | ០១ | ០១ | ០៣ | |
| *សរុប* | *៥៧ ករណី* | *៤៩៥ នាក់* | *៩៥ នាក់* | *០៣ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ៣៣ករណី/ ៣២ករណី (កើនឡើង ០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៣៩នាក់ (ស្រី ០៥នាក់) អនីតិជន ១០នាក់ និងជនបរទេស ០៤នាក់ សញ្ជាតិចិន ០២នាក់ និងបង់ក្លាដេស ០២នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៥៦នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ២៣នាក់ អាយុ១៥-១៧ឆ្នាំ ១៨នាក់ និងអាយុ១៨ឆ្នាំឡើង ១៥នាក់ (ប្រគល់ឱ្យគ្រួសារ ៥៦នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការចាប់ពង្រត់ ការឃុំឃាំងឬ ការបង្ខាំង | ០១ | ០២ | ០៤ | ចិន២ បង់ក្លាដេស២ |
| -សញ្ញារកម្ម(មានអនីតិជន) | ០១ | ០៤ | ០២ | |

| | | | | |
|---|---|---|---|---|
| -សញ្ញារកម្ម(មានអនីតិជន) | ០១ | ០៤ | ០២ | |
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមា | ០៥ | ២៤ | ០៦ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ០៤ | ០៤ | ០៤ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៩ | ១៩ | ២០ (អនី.១០) | |
| -អំពើអាសប្រឆាំងនឹងអនិតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | ០៣ | |
| *សរុប* | *៣៣ ករណី* | *៥៦ នាក់* | *៣៩ នាក់* | *០៤ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន ១០.៥០៩នាក់(ស្ត្រី ៤.០៧២នាក់) កុមារ ៨២២នាក់ (កុមារី ៥១៨នាក់)សកម្មភាពមានដូចជា៖

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានទទួលចំនួន ៥៩នាក់ (ស្ត្រី ៥១នាក់)កុមារ ០៧នាក់(កុមារី ០៥នាក) មកពីប្រទេសចិន ៥៥នាក់ និងម៉ាឡេស៊ី ០៤នាក់ ករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ/បង្ខំ ៥៥នាក់ និងជួញដូរកម្លាំងពលកម្ម ០៤នាក់ បានសម្ភាសន៍កំណត់អត្តសញ្ញាណ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។
- មណ្ឌលសំចតប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បានទទួលពីប្រទេសថៃចំនួន ១០.៤៥០នាក់ (ស្ត្រី ៤.០២១នាក់)កុមារ ៨១៥នាក់ (កុមារី ៥១៣នាក់) បានបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ ដើម្បីផ្តល់សេវជូនពលករមួយចំនួន ដែលមិនមានលទ្ធភាពត្រឡប់ទៅស្រុកកំណើតវិញបន្ទាប់ពីធ្វើចត្តាឡីស័ករួច។

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសន៍ជនរងគ្រោះដែលបានវិលត្រឡប់មកពីប្រទេសចិនតាមរយៈអនឡាញ ចំនួន ៩៤នាក់(ស្រី ៨៨នាក់) អនីតិជន ០៨នាក់(ស្រី) មកពីប្រទេសចិន ៨៧នាក់ ម៉ាឡេស៊ី ០៣នាក់ និងបង់ក្លាដេស០៤នាក់។ ជាលទ្ធផលជនរងគ្រោះដោយការកេងប្រវ័ញ្ចពលកម្ម ០២នាក់ ឆបោក ០៤នាក់ រៀបអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ ៨៦នាក់ ស្នាក់នៅប្រទេសចិនដោយខុសច្បាប់ ៤១នាក់ និងមិនរងគ្រោះ ០១នាក់។
- **ខេត្តបន្ទាយមានជ័យ៖** ក្រុមការងារបានទទួល នឹងសម្ភាសន៍ជនទេសន្តរប្រវេសន៍(ពលរដ្ឋខ្មែរ) ដែលអាជ្ញាធរថៃបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ចំនួន ១៨.១៧២នាក់(ស្ត្រី ៧.០៨១នាក់) អនីតិជន ២.១៦៤នាក់។
- **ខេត្តបាត់ដំបង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនមកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ចំនួន ០១លើក មនុស្សចំនួន ៥៥នាក់(ស្រី ២១នាក់ អនីតិជន ០៤នាក់)។

- **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនមកកម្ពុជាវិញ ចំនួន ២១លើក មនុស្សចំនួន ៦៧នាក់ (ស្រី ២៥នាក់ អនីតិជន ០៩នាក់)។
- **ខេត្តស្វាយរៀង៖** បានទទួលពលរដ្ឋខ្មែរដែលឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសវៀតណាម ចំនួន ០២លើក មនុស្សចំនួន ១៣នាក់ (ស្រី ០៧នាក់) អនីតិជន ០៧នាក់។
- **ខេត្តតាកែវ៖** បានទទួលពលករពីបរទេសសរុប ៦៩នាក់ (ស្រី ៣៦នាក់) ក្នុងនោះមកពីប្រទេសវៀតណាម ៥៧នាក់ (ស្រី ៣១នាក់) និងប្រទេសថៃ ១២នាក់ (ស្រី០៥នាក់)។

### ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ៩២នាក់(ស្ត្រី ៥៨នាក់)កុមារ ៣៤នាក់(កុមារី ៣២នាក់) ក្នុងនោះមាន៖ មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ២៥នាក់ មន្ទីរសង្គមកិច្ចខេត្តព្រះសីហនុ ០១នាក់ អង្គការក្តីស្រឡាញ់គ្មានព្រំដែន ១០នាក់ អង្គការ A21 ០៥នាក់ សមាគមកុមាររីករាយ ០៥នាក់ អង្គការសង្គ្រោះនិងថែទាំស៊ីធីភញ ០៩នាក់ អង្គការរេណាសេ ០៦នាក់ អង្គការយុត្តិធម៌និងក្តីសង្ឃឹម ១៥នាក់ និងអង្គការ World Mobilization ១៦នាក់។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅសហគមន៍វិញសរុបចំនួន ៥៦នាក់ (ស្ត្រី ៥០នាក់ កុមារី ០៤នាក់) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ/បង្ខំ ៥៤នាក់ ជួញដូរកម្លាំងពលកម្ម ០២នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | | | |
| | - បានបើកវគ្គបណ្តុះបណ្តាល ដល់មន្ត្រីស.អ.យ ក្រុង/ស្រុក/ខេត្ត លើ "គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ និងគោលការណ៍ណែនាំ ស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប" នៅខេត្តកំពង់ចាមចំនួន ១០ស្រុក និងខេត្តព្រៃវែងចំនួន១៣ស្រុក ដោយមានកិច្ចសហការគាំទ្រពី អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)។ | ០២ | ៣៤ | ០៩ |
| | - បានបើកវគ្គបណ្តុះបណ្តាល ដល់មន្ត្រីស.អ.យ ក្រុង/ស្រុក/ខេត្ត លើ "គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ និងវគ្គបណ្តុះបណ្តាល គោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសម ស្រប" | ០២ | ១០២ | ២៥ |

| | | | | |
|---|---|---|---|---|
| | នៅខេត្តកំពង់ចាម ដោយមានកិច្ចសហការគាំទ្រពីគម្រោងកម្មវិធី ASEAN-ACT។ | | | |
| ២ | **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** | | | |
| | - សហការជាមួយសាលាខេត្តបាត់ដំបង និងទទួលបានការឧបត្ថម្ភពីអង្គការ ASEAN-ACT បើកវគ្គបណ្តុះបណ្តាល ស្តីពី "ការកំណត់សញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាសមស្រប" នៅខេត្តបាត់ដំបង ស្រុកកំរៀង ភ្នំព្រឹក រុក្ខគិរី និងស្រុកសំពៅលូន។ | ០២ | ៦៩ | ០៦ |
| | - សហការសហការជាមួយសាលាខេត្តសៀមរាប អង្គការ A21 អង្គការ IJM និងអង្គការហាហ្កា បើកវគ្គបណ្តុះបណ្តាល តាមប្រព័ន្ធអនឡាញ ស្តីពី "ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូមនុស្ស ដើម្បីទទួលបានសេវាសមស្រប" ដល់មន្ត្រីរាជការ សមត្ថកិច្ច និងអង្គការពាក់ព័ន្ធ នៅខេត្តសៀមរាប។ | ០១ | ១៩១ | ៧៨ |
| ៣ | **ខេត្តសៀមរាប** | | | |
| | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការបន្ទាយស្រី បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់តំណាងសហគមន៍ក្នុងស្រុកអង្គរធំ រៀបចំដោយអង្គការបន្ទាយស្រី។ | ០១ | ១៥ | ០៨ |
| | - មន្ទីរកិច្ចការនារីខេត្ត បើកវគ្គបណ្តុះបណ្តាល ស្តីពីការគាំទ្រផ្លូវចិត្តសម្រាប់អ្នកផ្តល់សេវាដល់ជនរងគ្រោះ ដោយអំពើហិង្សាលើស្ត្រី រួមទាំងស្ត្រីពលករចំណាកស្រុក ដល់ក្រុមការងារឆ្លើយតបជាពហុវិស័យ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ តាមកម្មវិធី ZOOM។ | ០១ | ៣៩ | ១៤ |
| | - មន្ទីរកិច្ចការនារី សហការជាមួយរដ្ឋបាលស្រុកពួក និងរដ្ឋបាលស្រុកក្រឡាញ់ បើកវគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងមូលដ្ឋាន និងបច្ចេកទេសក្នុងការប្រើប្រាស់ប្រព័ន្ធ ZOOM ដល់ក្រុមការងារឆ្លើយតបជាពហុវិស័យ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបានការគាំទ្រពីក្រសួងកិច្ចការនារី និងអង្គការ UN WOMEN។ | ០៣ | ១៦៧ | ១០៦ |
| ៤ | **ខេត្តព្រះវិហារ៖** ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បានបើកវគ្គបណ្តុះបណ្តាលហ្វឹកហ្វឺនមូលដ្ឋានគ្រិះ ស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ ក្នុងការសម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះ តាមប្រព័ន្ធ ZOOM ។ | ០៤ | ១២០ | ២៨ |
| ៥ | **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន០៥ បើកវគ្គបណ្តុះបណ្តាល ដោយបានបញ្ជ្រាបការយល់ដឹង អំពីចំណាកស្រុកប្រកបដោយសុវត្ថិភាពរួមបញ្ចូលជាមួយនូវប្រធានបទ ស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារ | ០១ | ៩៦ | ៥៤ |

| | | | | |
|---|---|---|---|---|
| | ជាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អ ដើម្បីបង្កើនផលិតភាព ផលិតផល ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម។ | | | |
| ៦ | **ខេត្តព្រៃវែង៖** សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី(LSWCW) បើកវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងសំណុំករណី និងការបញ្ជូនករណីសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅកាន់សេវាគាំទ្រ។ | ០១ | ២០ | ១២ |
| ៧ | **ខេត្តតាកែវ៖** បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីបណ្តាញកិច្ចការពារកុមារ ដល់មន្ត្រីផ្តល់សេវាសង្គមកិច្ច និងអ្នកពាក់ព័ន្ធថ្នាក់ឃុំ សង្កាត់ចំនួន ១៥ឃុំ ក្នុងស្រុកបាទី តាមប្រព័ន្ធអនឡាញ គាំទ្រដោយអង្គការដៃគូផ្តល់មេត្តា(PC)និងICC។ | ០១ | ២៧៧ | ២០៨ |
| សរុប | | ១៩ វគ្គ | ១.១៣០ នាក់ | ៥៤៨ នាក់ |

## ក.២. សិក្ខាសាលា

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំសិក្ខាសាលាចំនួន ០២វគ្គ បណ្តុះបណ្តាលលើ "**គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ និងគោលការណ៍ណែនាំ ស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប**" នៅក្នុងខេត្តស្វាយរៀង សិក្ខាកាមចូលរួមសរុបចំនួន ៦០នាក់ (ស្រី ១៩នាក់) មានដូចជា: មន្ត្រីស.អ.យ ក្រុង/ស្រុក/ខេត្ត មេឃុំ មេភូមិ មន្ត្រីគ.ក.ន.ក គ្រូបង្រៀន គ្រូពេទ្យ ប៉ូលីសប៉ុស្តិ៍ ដោយមានកិច្ចសហការគាំទ្រពីគម្រោងកម្មវិធី ASEAN-ACT។
- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ** បានសហការគ្នាជាមួយអង្គការ IOM រៀបចំសិក្ខាសិលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ និងក្រមសីលធម៌ រវាងច្រកទេសន្តរប្រវេសន៍ការងារពីប្រទេសកម្ពុជាទៅប្រទេសថៃ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ សមាសភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ សរុបចំនួន ៥០នាក។
- **ខេត្តបាត់ដំបង៖** លេខាធិការដ្ឋានគ.ខ.ប.ជ សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដើម្បីកុមារ និងស្ត្រី រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងករណី និងការផ្តល់សេវាដល់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ចំនួន ០១វគ្គ នៅស្រុកឯកភ្នំ ខេត្តបាត់ដំបង។
- **SOMTC-Philippines** សហការជាមួយ **SOMTC-Cambodia** រៀបចំសិក្ខាសាលា ស្តីពីការបង្កើតប្រព័ន្ធទំនាក់ទំនងសម្រាប់មន្ត្រីបង្គោលតំណាងថ្នាក់ជាតិ ACTIP តាមប្រព័ន្ធ Zoom រយៈពេល ០២ថ្ងៃ សមាសភាពអញ្ជើញចូលរួមក្នុងកម្មវិធីនេះរួមមានតំណាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក SOMTC ខ្មែរ ថៃ និងហ្វីលីពីន អង្គការ ASla Foundation និងអ្នកសង្កេតការណ៍ខ្មែរ ថៃ និងហ្វីលីពីន សរុបចំនួន ៤៣នាក់។
- ក្រុមការងារគម្រោង **SPOTLIGHT Initiative** រៀបចំសិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហការឆ្លងកាត់ព្រំដែនក្នុងចំណោមអ្នកផ្តល់សេវាកម្មនៅម៉ាឡេស៊ី និងកម្ពុជាសម្រាប់ការផ្តល់សេវាកម្មឆ្លើយតបយេនឌ័រ និងការបញ្ជូនបន្តសម្រាប់ស្ត្រីចំណាកស្រុក តាមប្រព័ន្ធ Zoom សមាសភាពចូលរួមរួម

មានតំណាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រដ្ឋបាលស្រុកកំពង់ធំ តំណាងអនុព័ន្ធការងារកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី ក្រុមការងារ Spotlight Initiative និងពីអង្គការពាក់ព័ន្ធ សរុបចំនួន ៥៥នាក់។

- **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយស្នងការដ្ឋាននគរបាលខេត្ត និងអង្គការជីវិតនៅកម្ពុជា(TLC) រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីច្បាប់ ស្តីពីយុត្តិធម៌អនីតិជន និងកិច្ចការពារកុមារ ដល់ថ្នាក់ដឹកនាំជាអភិបាលរងស្រុក ប្រធានគ.ក.ស.ក ការិយាល័យសុខមាលភាពសង្គម មេឃុំចៅសង្កាត់ អ.ក.ន.ក ឃុំសង្កាត់ ទូទាំង១២ក្រុង ស្រុក និងឃុំ សង្កាត់ ចំនួន ០២លើក អ្នកចូលរួមចំនួន ២៦០នាក់ (ស្រី៨៧នាក់)។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ
  - បានបើកជំនួបកិច្ចប្រជុំពិនិត្យនិងពិភាក្សា ស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា ភាគី គ.ជ.ប.ជ ដឹកនាំដោយលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួង មហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ភាគីស្ថានទូតអាមេរិកដឹកនាំដោយ ឯកឧត្តម **W. Patrick Murphy** ឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ កិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ កិច្ចប្រជុំនេះមានការចូលរួមពីសមាសភាព ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអង្គការដៃគូ សរុបចំនួន ៣៤នាក់ (ស្រី ១០នាក់) មកពី ក្រសួង ស្ថាប័ន និងអង្គភាព នៅសាលប្រជុំក្រសួងយុត្តិធម៌។
  - បានរៀបចំកិច្ចប្រជុំ ឆ្លងរបាយការណ៍១០ខែ ឆ្នាំ២០២១ ស្តីពី "ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស" តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ មានអ្នកចូលរួមប្រមាណ ១៣៥នាក់។
- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំ៖

- កិច្ចប្រជុំកម្រិតជំនាញត្រៀមពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់ តាមប្រព័ន្ធអនឡាញជាមួយអង្គការ IOM មានការអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ លោកស្រី ប្រធានអង្គការ IOM ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋានរដ្ឋបាល-សរុប ប្រធានក្រុមជំនួយកិច្ចការទាំង៦ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងស្ថាប័នពាក់ព័ន្ធ សរុបចំនួន ១២០នាក់។
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រៀងឯកសារកែសម្រួល MOU ជាមួយអង្គការ Hagar ចំនួន ០៣លើក មានការអញ្ជើញចូលរួមពី លោកជំទាវ អគ្គលេខាធិការ លោកជំទាវ ឯកឧត្តម អគ្គលេខាធិការរង និងតំណាងអង្គការ Hagar នៅសាលប្រជុំ គ.ជ.ប.ជ។
- កិច្ចប្រជុំពិភាក្សា ករណីផ្សព្វផ្សាយ តាមប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលមានលក្ខណៈស្រើបស្រាល និងអាសអាភាស តាមប្រព័ន្ធអនឡាញ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី អគ្គព្រះរាជអាជ្ញារង

អមសាលាឧទ្ទរណ៍ ថ្នាក់ដឹកនាំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងពីអន្តរក្រសួងមាន ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងអប់រំយុវជន និងកីឡា ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងតំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ។

- កិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ស្តីពី «**ការគ្រប់គ្រងចំណាកស្រុក**» តាមប្រព័ន្ធអនឡាញ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួម ពីថ្នាក់ដឹកនាំរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អង្គការដៃគូអភិវឌ្ឍ មាន IOM, ILO, WHO, UNICEF, UNRCO តំណាងពីអន្តរក្រសួងស្ថាប័ន មានតំណាងពីក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច ក្រសួងការងារបណ្តុះ ក្រសួងការបរទេស ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ប្រធានអង្គភាព និងអភិវឌ្ឍន៍គោលនយោបាយរបស់ លេខាធិការដ្ឋានគ.ជ.អ.ប អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គអត្តសញ្ញាណកម្ម ទីចាត់ការព្រំដែន នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានព្រំដែនទឹក នាយកដ្ឋានព្រំដែនគោក អគ្គស្នងការនគរបាលជាតិ មន្ត្រីបច្ចេកទេស សរុបមួយចំនួន ៤៥នាក់។
- កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌ និងក្រមសីលធម៌ រវាងច្រកទេសន្តរប្រវេសន៍ការងារពីប្រទេសកម្ពុជាទៅប្រទេសថៃ តាមប្រព័ន្ធអនឡាញ សហការគ្នាជាមួយអង្គការ IOM ការពិគ្រោះយោបល់ថ្នាក់ជាតិនេះ ជាវេទិកាមួយសម្រាប់ តំណាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និយោជក អ្នកជ្រើសរើសការងារ និងសមាគមរបស់ខ្លួន សង្គមស៊ីវិល និងអង្គការពាក់ព័ន្ធការងារពលករ និងកម្មករ ដើម្បីចូលរួម កិច្ចសន្ទនាស្តីពីការជំរុញការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងការប្តេជ្ញាចិត្តរបស់វិស័យឯកជន ទាក់ទងនឹងការជ្រើសរើស ពលករចំណាកស្រុកកម្ពុជា។
- កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការអនុវត្តផែនការជាតិ សម្រាប់ការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) ដោយមានការចូលរួមសហការពីអង្គការ IOM ប្រចាំកម្ពុជា។
- ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីពិនិត្យលទ្ធផលបឋមនៃការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្ត្រជាតិ០៥ឆ្នាំ ២០១៩-២០២៣ តាមប្រព័ន្ធវីដេអូ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ជាសមាជិក គ.ជ.ប.ជ លោកជំទាវអគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អង្គការដៃគូអភិវឌ្ឍដែលពាក់ព័ន្ធ ក្នុងកិច្ចការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ ។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានរៀបចំកិច្ចប្រជុំ៖
  - ក្រុមការងារបច្ចេកទេសចង្អៀត ដើម្បីរៀបចំនីតិវិធីការអនុវត្តគោលការណ៍ណែនាំ នៃដំណើរការមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០៣លើក មានអ្នកចូលរួមចំនួន ៣២នាក់ (ស្រី ១០នាក់។
  - ថ្នាក់បច្ចេកទេសដើម្បីត្រៀមប្រជុំជាមួយភាគីថៃ ស្តីពីការពិនិត្យ ពិភាក្សាលើទម្រង់គ្រប់គ្រងករណី និងឧបសម្ព័ន្ធក្នុងការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន(SOPs) ចំនួន ០៣លើក មានអ្នកចូលរួមចំនួន ២៧នាក់ (ស្រី ០៥នាក់)។

- អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ៖
  - បានរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីការត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួមប្រមាណ ៦៣នាក់។
  - ពិធីចុះកិច្ចព្រមព្រៀងអំពីកិច្ចសហការគ្នា ស្តីពីការផ្លាស់ប្តូរឥរិយាបថបុគ្គល និងសហគមន៍ ដើម្បីលើកកម្ពស់សុវត្ថិភាពជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស រវាង គ.ជ.ប.ជ ជាមួយអង្គការ មូលនិធិហាហ្គា អន្តរជាតិ នៅសាលប្រជុំគ.ជ.ប.ជ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង លោកស្រី កុយ គៀង ប្រធានអង្គការហាហ្គា ប្រចាំកម្ពុជា មានអ្នកចូលរួមចំនួន ១៦នាក់ (ស្រី ០៤នាក់)។

## ខ.២. ទស្សនកិច្ច

- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអញ្ជើញជាអធិបតីភាព ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ មណ្ឌលទទួលពលករកំរៀង ព្រមទាំងសមិទ្ធផលនានាក្នុងមណ្ឌល ដែលមានទីតាំងស្ថិតនៅក្នុង ភូមិបឹងរាំង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង មានអ្នកចូលរួមសរុបប្រមាណ ៦០០នាក់។
- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងឯកឧត្តម **ម៉ៅ តាន់អ៊ាន** ទីប្រឹក្សាក្រសួងសុខាភិបាល បានដឹកនាំប្រតិភូ ធ្វើដំណើរទស្សនកិច្ច និងប្រជុំពិភាក្សាការងារ ស្តីពីការចុះសិក្សាប៉ាន់ប្រមាណពីស្ថានភាពលំហូរប្រជាពលរដ្ឋ និងពលករទេសន្តរប្រវេសន៍ ស្វែងយល់អំពីតំរូវការលើបញ្ហាសុខភាព ដើម្បីប្រមូលធាតុចូលសំរាប់ផែនការយុទ្ធស្រ្តនៃគោលនយោបាយជាតិស្តីពី សុខភាពជនទេសន្តរប្រវេសន៍ នៅច្រកព្រំដែនអន្តរជាតិ ដូង បុស្សមន ព្រៃវល្លិ៍ បាវិត នៃខេត្តស្វាយរៀង។

## ខ.៣. ជំនួបពិភាក្សាការងារ

- ថ្នាក់ជាតិ
  - គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជួបពិភាក្សាការងារ៖
    - ជាមួយប្រធាននិងសហការី របស់អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការ Terres de hommes តាមប្រព័ន្ធអនឡាញ ស្តីពីកិច្ចសហប្រតិបត្តិការ និងផែនការការអនុវត្តគម្រោង៣ឆ្នាំ ចំនួន៦ខេត្តគោលដៅ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរ ដើម្បីផ្តល់សេវា សមស្រប និងការងារពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
    - ជាមួយប្រធាន និងសហការី របស់អង្គការសម្ព័ន្ធចាប់ដៃ ពាក់ព័ន្ធនឹងកិច្ចសហការការងារ ក្នុងវិស័យប្រឆាំងការជួញដូរមនុស្ស។
    - ជាមួយលោក ERIKSHJALPEN ប្រធានអង្គការអភិវឌ្ឍន៍អេរិក្ស(Eric) ដើម្បីពិភាក្សាលើអនុស្សរណៈនៃការយោគយល់រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដៃគូអភិវឌ្ឍន៍អេរិក្ស ស្តីពី **"សកម្មភាពបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំង រាល់ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗ និងអំពើជួញដូរកុមារ"** នៅសាលប្រជុំ គ.ជ.ប.ជ។

- ថ្នាក់ក្រោមជាតិ
  - ខេត្តសៀមរៀប៖
    - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិកាដ្ឋាន គ.ខ.ប.ជ បានទទួល ជួបពិភាក្សាការងារជាមួយអង្គការមូលនិធិអេ២១ ស្តីពីការរៀបចំព្រឹត្តិការណ៍ រួមគ្នាបញ្ឈប់អំពើជួញដូរមនុស្ស។

○ ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារ ជាមួយអង្គការជីវិតនៅកម្ពុជា ស្តីពីការរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីច្បាប់ ស្តីពីយុត្តិធម៌អនីតិជន និងកិច្ចការពារជនរងគ្រោះ។

- **ខេត្តបាត់ដំបង៖** លេខាធិការដ្ឋានគ.ខ.ប.ជ បានជួបពិភាក្សាការងារក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការយូនីសេហ្វ ស្តីពីកិច្ចការពារកុមារ នៅសាលាខេត្តបាត់ដំបង។
- **ខេត្តព្រៃវែង៖** លោកនាយករងរដ្ឋបាលសាលាខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គ.ខ.ប.ជ និងសហការី បានជួបពិភាក្សាការងារជាមួយ ក្រុមការងារនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីស្វែងយល់ពីក្រមសីលធម៌ និងសិទ្ធិរបស់អ្នកត្រូវធ្វើចត្តាឡីស័ក ពិសេសស្ត្រី និងកុមារជាជនទេសន្តរប្រវេសន៍មកពីក្រៅប្រទេស មានអ្នកចូលរួមចំនួន ០៧នាក់ (ស្រី ០១នាក់)។
- **ខេត្តកណ្តាល៖** លោកជំទាវ ហ៊ិន កុសនី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ និងក្រុមការងារ បានជួបពិក្សាការងារជាមួយក្រុមជំនាញការនៃអង្គការនៃក្តីសង្ឃឹម និងយុត្តិធម៌ (Hope of Justice) អំពីការងារពាក់ព័ន្ធទៅនឹងការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ០១លើក។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ១៩៣លើក មានអ្នកចូលរួមសរុប ៤.៤៦៣នាក់ (ស្រី ១.៥៩៨នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ៥៧លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០២លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន ១៣៤លើក។(ឧបសម្ព័ន្ធ១)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ណយភឌ

- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅអនុវត្តបន្ត ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

**ក.ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ**

ក.១. គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ដើម្បីបន្តពិគ្រោះយោបល់ និងពិនិត្យឡើងវិញខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីអំពើពោះជំនួស។

ក.៣. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសកិច្ចសហការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ ។

ក.៤. បន្តពង្រឹង និងជំរុញការអនុវត្ត អនុស្សរណៈ កិច្ចព្រមព្រៀង ស្តង់ដារនៃនីតិវិធីប្រតិបត្តិ ដែលមានស្រាប់ជាមួយបណ្តាប្រទេស និងដៃគូពាក់ព័ន្ធ។

ក.៥. ត្រៀមចុះហត្ថលេខាលើស្តង់ដារនៃនីតិវិធីប្រតិបត្តិ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាង រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការអនុវត្តច្បាប់។

ក.៦. ត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍របស់ក្រសួងសុខាភិបាល។

ក.៧. រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីកសាងបទដ្ឋានគតិយុត្តិនានា សម្រាប់ការពារសិទ្ធិសុវត្ថិភាព ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទសមុទ្រ។

ក.៨. ត្រៀមកិច្ចប្រជុំបួនប្រទេស កម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា ក្នុងការពង្រឹងកិច្ចសហការ ការពារ និងបង្ការ ទប់ស្កាត់ ការនាំមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេសស្ត្រី និងកុមារ ក៏ដូចជាទារក។

ក.៩. ត្រៀមបន្តចុះហត្ថលេខាអនុស្សរណៈ/កិច្ចព្រមព្រៀងសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធ។

**ខ.ការងារបង្ការ ទប់ស្កាត់**

ខ.១. សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំយុទ្ធនាការ "គាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម"។

ខ.២. ត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សៀវភៅសិក្សាអប់រំស្តីពី "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន" សម្រាប់ដាក់បញ្ចូលក្នុងកម្មវិធីសិក្សាកម្រិត បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

ខ.៣. ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ធ្វើការបោះពុម្ពសៀវភៅសិក្សាអប់រំស្តីពី "ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន" និងបើកវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ គ្រូឧទ្ទេសគរុកោសល្យភូមិភាគ និងគ្រូបង្គោល តាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ នៅទូទាំងប្រទេស។

ខ.៤. សហការជាមួយអង្គការដៃគូ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីរកវិធានការទប់ស្កាត់អំពើរំលោភបំពានគ្រប់ទម្រង់លើកុមារ។

ខ.៥. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយ ទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដើម្បីជំរុញ និងពង្រីកការផ្សព្វផ្សាយអំពី ឱកាសការងារឱ្យកាន់តែទូលំទូលាយ នៅតាមសហគមន៍ ជាពិសេសសហគមន៍ដែលងាយរងគ្រោះ រួមទាំងពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់។

ខ.៦. សហការជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតនីតិវិធីងាយស្រួលក្នុងការផ្សារភ្ជាប់ទំនាក់ទំនង និងការទទួលបានការប្រឹក្សាយោបល់ពីទីភ្នាក់ងារជាតិមុខរបរ និងការងារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីជម្រើសការងារ ឬមុខរបរ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្សេងៗ សម្រាប់ក្រុមជនងាយរងគ្រោះ ជាពិសេស ពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់ពីបរទេស។

ខ.៧. បន្តជំរុញការគ្រប់គ្រង និងធ្វើអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីធានាការអនុវត្តគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារ ក្នុងការការពារសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដល់ពលករក្នុងការធ្វើទេសន្តរប្រវេសន៍ការងារ។

ខ.៨. បន្តរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ និងវេទិកាជាតិអន្តរសាសនានៅកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ខ.៩. បន្តសហការជាមួយអង្គការសហប្រជាជាតិ (IOM, WHO, UNFPA, UNICEF) និងដៃគូផ្សេងៗទៀត ដើម្បីរៀបចំកម្មវិធី ឆ្លើយតបទៅនឹងផលប៉ះពាល់លើសុខភាព និងជីវភាព ពលករទេសន្តរប្រវេសន៍ និងគ្រួសារ ក្នុងស្ថានភាពនៃការរាតត្បាតដោយជំងឺកូវីដ ១៩ និងគ្រោះមហន្តរាយផ្សេងៗទៀត។

ខ.១០.បន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ការផ្សព្វផ្សាយអំពីការបង្ការ ទប់ស្កាត់ ការឆ្លង និងចម្លងជំងឺកូវីដ ១៩ និងផលប៉ះពាល់ ព្រមទាំងចុះតាមដានការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ។

ខ.១១.បន្តលើកកម្ពស់ការងារផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងពង្រីកការអប់រំតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានទូលំទូលាយ អំពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងនិងក្រៅសាលារៀន និងជនងាយរងគ្រោះដទៃទៀត។

ខ.១២.បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេស អធិការកិច្ចដោយមិនជូនដំណឹងជាមុន ដើម្បីកំណត់រកអំពើកេងប្រវ័ញ្ចផ្សេងៗ និងមានវិធានការ ក្នុងប្រភេទការងារដែលមានភាពរងគ្រោះខ្ពស់ ដូចជានៅតាមរោងចក្រសហគ្រាស សហគ្រាសឡឥដ្ឋ កសិដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ កន្លែងសេវាកម្សាន្ត ជាដើម។

ខ.១៣.បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេស អធិការកិច្ចដោយមិនជូនដំណឹងជាមុន ចំពោះទីភ្នាក់ងារជ្រើសរើសពលករឯកជន។

ខ.១៤.លើកកម្ពស់ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ និងការអនុវត្តក្រមសីលធម៌ របស់ទីភ្នាក់ងារ និងកាត់បន្ថយការយកថ្លៃឈ្នួលពីពលករ ក្នុងនីតិវិធីនៃការជ្រើសរើសពលករទេសន្តរប្រវេសន៍។

ខ.១៥.បន្តរៀបចំផែនការអនុវត្តគោលបំណងអាទិភាព GCM និងអនុសញ្ញាអាស៊ាន ។

**គ.ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ**

គ.១. បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

គ.២. បន្តស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប និងផ្តន្ទាទោស បទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស ។

គ.៣. បន្តពង្រឹងកិច្ចសហការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការ ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត ប្រមូលភស្តុតាង ដើម្បីដាក់បន្ទុកជនល្មើសជួញដូរមនុស្ស។

គ.៤. បន្តពង្រឹងកិច្ចសហការជាមួយសមត្ថកិច្ចប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន។

គ.៥. ជំរុញការអនុវត្តនីតិវិធី នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

**ឃ.ការងារការពារជនរងគ្រោះ**

ឃ.១. ពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករ នៅក្នុងវដ្តនៃទេសន្តរប្រវេសន៍ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំ គោលនយោបាយ និងវិធានការសម្រាប់ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ ជាពិសេស ដើម្បីផ្តល់ សេវាជូនពលករដែលត្រូវបានបញ្ជូនត្រឡប់ដោយអាជ្ញាធរបរទេស និងពលករដែលវិលត្រឡប់ពីប្រទេសគោលដៅតាមច្រកព្រំដែនសំខាន់ៗ។

ឃ.២. សហការជាមួយអង្គការការីតាសស្វីស និងរដ្ឋបាល ខេត្តបាត់ដំបង សាងសង់ និងដាក់ឱ្យដំណើរការមណ្ឌលទទួលពលករ នៅស្រុកកំរៀង។

ឃ.៣. រៀបចំយន្តការសម្រាប់ការទទួលពលករ និងការគ្រប់គ្រង និងដំណើរការមណ្ឌលទទួលពលករ ស្រុកកំរៀង ខេត្តបាត់ដំបង ដោយមានកិច្ចសហការពីបណ្តា ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ពាក់ព័ន្ធ និងអង្គការដៃគូ ក្នុងការផ្តល់សេវា។

ឃ.៤. រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារ ក្នុងទេសន្តរប្រវេសន៍ ពីអំពើជួញដូរមនុស្ស និងការរំលោភបំពាន ។

ឃ.៥. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ៖

- គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- គោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដល់មន្ត្រីជួរមុខ។
- កម្មវិធីគ្រប់គ្រងករណីដល់មន្ត្រីដែលអនុវត្ត និងអ្នកពាក់ព័ន្ធទាំង២៥ រាជធានី ខេត្ត។

ឃ.៦. ធ្វើបច្ចុប្បន្នលើសារាចរ ស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយសារការជួញដូរមនុស្ស (SOPs) រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

ឃ.៧. បន្តកិច្ចសហប្រតិបត្តិការជាមួយ៖

- ក្រសួងយុត្តិធម៌ដើម្បីរៀបចំឱ្យមានមន្ត្រីសង្គមកិច្ចចូលរួមក្នុងប្រព័ន្ធតុលាការ នៅតាមសាលាដំបូងរាជធានី ខេត្ត។
- ក្រសួងសុខាភិបាល ក្នុងការជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទទួលបានសេវាពិនិត្យសុខភាព និងការព្យាបាលដោយឥតគិតថ្លៃ នៅតាមមជ្ឈមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋ។
- ស្ថានទូត និងកុងស៊ុល នៅក្រៅប្រទេស(តាមរយៈក្រសួងការបរទេស) ដើម្បីជួយដល់ជនរងគ្រោះ និងសម្រួលដល់ដំណើរការមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាឱ្យបានឆាប់រហ័ស និងមានសុវត្ថិភាព។
- ក្រសួងស្ថាប័ន និងអង្គការដៃគូ ដែលធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- មន្ត្រីថ្នាក់ក្រោមជាតិ ក្នុងដំណើរការស្វែងរក ប៉ាន់ប្រមាណគ្រួសារ តាមដាន សមាហរណកម្ម និងបិទករណីរបស់ជនរងគ្រោះ។
- ភាគីថៃសម្រាប់ដំណើរការកសាងមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

ឃ.៨. បន្តចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ឃ.៩. ពិនិត្យលទ្ធភាពដើម្បីបង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះជារបស់រដ្ឋ។

ឃ.១០.គាំទ្រក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធនៅក្នុងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសគោលដៅ អំពីគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋម ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

ឃ.១១.រៀបចំឧបករណ៍វាយតម្លៃអំពី ភាពប្រឈម និងមេរៀនទទួលបាន នៃ«**ការអនុវត្តនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប**» ក្នុងខេត្ត ដែលបានបណ្តុះបណ្តាលរួចហើយ ។

ឃ.១២.រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការផ្តល់សេវា ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស នៅតាមមណ្ឌល និងនៅតាមសហគមន៍។

**ង.ការងារពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ**

ង.១. ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធ ដល់មន្ត្រីទទួលបន្ទុកអនុវត្តថ្នាក់ក្រោមជាតិ លើការងារលេខាធិការដ្ឋាន ការងាររបាយការណ៍ ការកសាងផែនការ និងការងារត្រួតពិនិត្យ វាយតម្លៃ។

ង.២. ធ្វើការប៉ាន់ប្រមាណ និងវាយតម្លៃ ពាក់កណ្តាលអាណត្តិ ទៅលើការអនុវត្តផែនការយុទ្ធសាស្រ្តជាតិ ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ង.៣. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរៀបចំយន្តការប្រមូលទិន្នន័យថ្នាក់ជាតិ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាពិសេសទិន្នន័យនៃការអនុវត្តច្បាប់ ការផ្តន្ទាទោស និងការងារការពារជនរងគ្រោះឱ្យមានសង្គតិភាព។

ង.៤. គាំទ្រពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រងគ្រប់ផ្នែក ដល់មន្ត្រីជំនាញក្នុងក្រុមការងារ និង លេខាធិការដ្ឋានរាជធានី-ខេត្ត ដើម្បីពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

ង.៥. បន្តធ្វើសេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការរាជធានី ខេត្ត ។

ង.៦. រៀបចំប្រព័ន្ធប្រមូល ចងក្រង និងចែកចាយទិន្នន័យ តាមផ្នែកពាក់ព័ន្ធសំខាន់ៗ ។

ថ្ងៃ.................ខែ...........ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី...........ខែ...........ឆ្នាំ២០២២

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ១៩៣លើក) មនុស្សចំនួន ៤.៤៦៣នាក់ (ស្រី ១.៥៩៨នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>◦ ដឹកនាំថ្នាក់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងទីប្រឹក្សាក្រសួងសុខាភិបាល ធ្វើទស្សនកិច្ចសិក្សាវាយតម្លៃ អំពីស្ថានភាពនិងតម្រូវការរបស់ពលករទេសន្តរប្រវេសន៍ក្នុងតំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩ ខេត្តកោះកុង។<br>◦ ជួបពិភាក្សាការងារជាមួយមន្ត្រីមានសមត្ថកិច្ច នៅច្រកទ្វារអន្តរជាតិចាំយាម ខេត្តកោះកុង មានអភិបាលរងខេត្ត ប្រធានច្រកព្រំដែនចាំយាម មន្ត្រីបច្ចេកទេសសុខាភិបាល និងអង្គការIOM តំណាងធនាគារ ADB។<br>◦ ជួបពិភាក្សាការងារជាមួយកងកម្លាំងវរព្រំដែនសេនាតូចការពារព្រំដែនគោកលេខ៨២៧ ខេត្តកោះកុង។<br>◦ សិក្ខាសាលា ស្តីពីការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិ ប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ក្រោមអធិបតីភាព ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក.ជ.ក។<br>◦ ជាអធិបតីភាព ក្នុងពិធីវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ នៅខេត្តសៀមរាប ដោយមានកិច្ចសហការជាមួយអង្គការ A២១ និងមានការចូលរួមពីមន្ត្រីជំនាញ អង្គការដៃគូពាក់ព័ន្ធមួយចំនួន សរុបប្រមាណ ២០០នាក់។<br>◦ បើកវគ្គបណ្តុះបណ្តាល ស្តីពីការសម្ភាស និងកោសល្យវិច្ច័យបែបកុមារមេត្រី ដែលមានការសហការគាំទ្រពីអង្គការAPLE និងអង្គការអេ២១ នៅខេត្តសៀមរាប។<br>◦ សិក្ខាសាលាចែករំលែក ផ្សព្វផ្សាយលទ្ធផលវាយតម្លៃការអនុវត្តគម្រោងការការពារ និងសិទ្ធិកុមារនៅកម្ពុជា ដោយមានកិច្ចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយនឹងអង្គការតំណក់ទឹក និងអង្គការការីតាសស្វីស និងEU នៅសណ្ឋាគារពូលូវ៉ើ រាជធានីភ្នំពេញ។<br>◦ កិច្ចប្រជុំពិភាក្សា ស្តីពីគម្រោងអភិវឌ្ឍន៍សមត្ថភាពកាសាបរទេស(ខ្មែរ-ថៃ) និងការចុះក្នុងតំបន់ដើម្បីសួរសុខទុក្ខ ការអនុវត្តន៍គម្រោងនៅតាមសាលារៀនក្នុងខេត្តកោះកុង ដោយមានកិច្ចសហការគាំទ្រដោយ អង្គការផ្លែនអន្តរជាតិ(Plan) អង្គការសម្ព័ន្ធចាប់ដៃ អង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរមនុស្ស(Cambodia Acts)។<br>◦ ដឹកនាំប្រតិភូចុះត្រួតពិនិត្យទីតាំង និងការរៀបចំសម្រាប់ប្រារព្ធពិធី សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមណ្ឌលទទួលពលករស្រុកកំរៀង ស្ថិតនៅក្នុងភូមិអូរដា ឃុំអូររាំង ស្រុកកំរៀង ខេត្តបាត់ដំបង។<br>◦ ពិធីបិទកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីផែនការយុទ្ធសាស្ត្រជាតិ សុខភាពជនទេសន្តប្រវេសន៍ រយៈពេល១០ឆ្នាំ (២០២១-២០២៣) រៀបចំដោយក្រសួងសុខាភិបាល នៅសណ្ឋាគារអិលប៊ីអិន ក្រុងកំពង់ចាម ខេត្តកំពង់ចាម មានអ្នកចូលរួមចំនួន៥០នាក់ ស្រី០៦នាក់។ |

- កិច្ចប្រជុំប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អាណត្តិឆ្នាំ ២០១៨-២០២៣ នៅខេត្តសៀមរាប ដោយមានការឧបត្ថម្ភគាំទ្រដោយអង្គការផ្លែនអន្តរជាតិ ក្រោមអធិបតីភាព ឯកឧត្តម **វង់ សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធាន ក.ក.ជ។
- កម្មវិធី អបអរសាទរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២១ លើកទី១៥ របស់រដ្ឋបាលខេត្តសៀមរាប។
- ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០២១ លើកទី១៥ ក្រោមប្រធានបទ "**សូមកុំយកកូវីដ ១៩ ជាឱកាសប្រព្រឹត្តអំពើជួញដូរមនុស្ស**" របស់ គ.ខ.ប.ជ ខេត្តកំពង់ឆ្នាំង។
- បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅស្រុកអន្លង់វែង និងស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ដោយមានកិច្ចសហការ ជាមួយអង្គការអាស៊ានអាក់(ASEAN ACT) មានអ្នកចូលរួមចំនួន៦៣នាក់ (ស្រី២៦នាក់)។

▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖

- កិច្ចប្រជុំ ស្តីពីកិច្ចពិភាក្សាបន្ត សម្រាប់ត្រៀមប្រជុំទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៏ លើឧសម្ពន្ធ័ ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមអនឡាញ ដែលរៀបចំឡើងដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- ដឹកនាំកិច្ចប្រជុំពិនិត្យកែតម្រូវ និងរៀបចំឃ្លោងឃ្លា អនុស្សារណៈនៃការយោគយល់គ្នាជាមួយអង្គការមូលនិធិហាការអន្តរជាតិ ស្តីពីការលើកកម្ពស់វិស័យសេដ្ឋកិច្ច សម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ អំពើហិង្សាធ្ងន់ធ្ងរផ្តេកលើយ៉េនឌ័រ និងពលករចំណាកស្រុក ដែលបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ។
- សិក្ខាសាលា ស្តីពីការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិ ប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ក្រោមអធិបតីភាព ឯកឧត្តម **វង់ សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក.ជ.ក។
- កិច្ចប្រជុំ ក្រុមលេខាធិការដ្ឋាន ក្រុមការងារបច្ចេកទេសសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ កិច្ចប្រជុំមានការអញ្ជើញចូលរួមសហការពីក្រុមការងារពាក់ព័ន្ធលើការងារទេសន្តរប្រវេសន៍ ក្រសួងសុខាភិបាល និងក្រុមការងារអង្គការអន្តរជាតិទេសន្តរប្រវេសន៍(International Organization for Migration) (IOM) នៅបន្ទប់ប្រជុំហាងកាហ្វេ(Coffee de Jenny)។
- កិច្ចប្រជុំលើកទី២ របស់ក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ ដើម្បីស្វែងយល់ពីគោលបំណងធំៗចំនួន៦ ពាក់ព័ន្ធដល់វឌ្ឍនភាពនៃការអនុវត្តអនុសញ្ញាអាស៊ាន ប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ(ACTIP) សហការរៀបចំដោយ ក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា និងដឹកនាំ សម្របសម្រួលដោយ ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងជាប្រធានក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។
- ដឹកនាំកិច្ចប្រជុំពិភាក្សាការងារ ជាមួយអង្គការក្តីសង្ឃឹម ដើម្បីយុត្តិធម៌នៅកម្ពុជា ស្តីពីតម្រូវការរបស់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប នៅសាលប្រជុំគ.ជ.ប.ជ។

- កម្មវិធីដាំកូនឈើ និងបើកសិក្ខាសាលា ស្តីពីសិទ្ធិកុមារ កិច្ចការពារកុមារ និងច្បាប់នានាពាក់ព័ន្ធនឹងកិច្ចការពារកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការជួញដូរមនុស្ស និងវិធីសាស្ត្រសង្គ្រោះផ្លូវចិត្តបឋម នៅមណ្ឌលទទួលពលករកំរៀង។
- អមដំណើរលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ធ្វើដំណើរទស្សនកិច្ចសិក្សាវាយតម្លៃស្ថានភាពហេតុ និងតម្រូវការរបស់ពលករទេសន្តប្រវេសន៍ ក្នុងដំណាក់កាលនៃវិបត្តិកូវីដ-១៩ នៅខេត្តព្រៃវែង និងស្វាយរៀង។
- កិច្ចពិភាក្សា ស្តីពីការសាងសង់មណ្ឌលសំចត និងទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនងាយរងគ្រោះដទៃទៀត នៅប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក្រោមអធិបតីភាពឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ តាមប្រព័ន្ធZoom នៅសាលប្រជុំ គ.ជ.ប.ជ។
- កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីពិនិត្យលទ្ធផលបឋម នៃការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្ត្រជាតិ០៥ឆ្នាំ (២០១៩-២០២៣) តាមប្រព័ន្ធZOOM ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។
- សិក្ខាសាលាថ្នាក់ជាតិតាមប្រព័ន្ធអនឡាញ ស្តីពីការបង្ហាញរបកគំហើញសំខាន់ៗ នៃការសិក្សាស្រាវជ្រាវ ពាក់ព័ន្ធកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយមានកិច្ចសហការរៀបចំឡើងដោយក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ាន អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា(ASEAN-ACT) នៅសាលប្រជុំគ.ជ.ប.ជ។
- កិច្ចពិភាក្សានីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ នៅខេត្តសៀមរាប។
- ពិធីបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលការសង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្ត ទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស រៀបចំឡើងដោយអង្គការ IOM នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប។
- ដឹកនាំកិច្ចប្រជុំ ស្តីពីការព្រាងឯកសារសមិទ្ធផល១០ខែ ឆ្នាំ២០២១ សម្រាប់ធ្វើបទបង្ហាញ និងការរៀបចំផែនការបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប សម្រាប់ខេត្តឧត្តរមានជ័យ។

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៤៨ច្បាប់ លិខិតចូល ៣០ច្បាប់។
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ៣៧ច្បាប់ លិខិតចូល ២៧ច្បាប់។
- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។
- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែតុលា វិច្ឆិកា ធ្នូ ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- បូកសរុបរបាយការណ៍ខែតុលា វិច្ឆិកា ធ្នូ និងត្រីមាសទី៤ ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។

- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។
- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី ៧៧សកម្មភាព។
- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្ដាញសង្គម និងគេហទំព័រនានា។
- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ Wiki ncct Convert ជា PDF បានចំនួន ២៤៥ច្បាប់។

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

- លោកឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួមកិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ ស្ដីពីគ្រោងផ្លាស់ប្ដូរការបង្រៀនទៅវិញទៅមកសម្រាប់កុមារដែលរស់នៅជាប់ព្រំដែនខ្មែរ។
- លោកឧត្តមសេនីយ៍ទោ **រ៉ន សុភ័ក្ត្រវឌ្ឍនា** ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញចូលរួមសិក្ខាសាលាចែករំលែក ផ្សព្វផ្សាយលទ្ធផលវាយតម្លៃការអនុវត្តគម្រោងការការពារ និងសិទ្ធិកុមារនៅកម្ពុជា ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ដោយមានកិច្ចសហការរវាង គ.ជ.ប.ជ និងអង្គការតំណក់ទឹក អង្គការការីតាសស្វីស និងEU នៅសណ្ឋាគារពូលូវ៉ែ រាជធានីភ្នំពេញ។

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

- ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កិច្ចប្រជុំស្ដីពីកិច្ចពិភាក្សាបន្ត សម្រាប់ត្រៀមប្រជុំទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ដ៍ លើឧសម្ពន្ធ័ ស្ដីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមអនឡាញ ដែលរៀបចំឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
  - សិក្ខាសាលាពិគ្រោះយោបល់ ស្ដីពីសេចក្ដីព្រាងច្បាប់ដំបូងកិច្ចការពារកុមារ នៃព្រះរាជាណាចក្រកម្ពុជា ជាមួយអន្តរក្រសួង និង អង្គការដៃគូពាក់ព័ន្ធ ក្រោមអធិបតីភាព លោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមប្រព័ន្ធអនឡាញ។
  - សិក្ខាសាលាស្ដីពី ការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិ ប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក.ជ.ក។
  - កិច្ចប្រជុំពិភាក្សា ដើម្បីត្រៀមប្រជុំទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ លើកឧបសម្ព័ន្ធ ស្ដីពីការបញ្ជូន ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ។
  - វគ្គបណ្ដុះបណ្ដាល ស្ដីពីសុវត្ថិភាពការងារប្រើប្រាស់បណ្ដាញទំនាក់ទំនងសង្គម ក្រោមអធិបតីភាព លោកជំទាវ **ញ៉េប សុភាព** អគ្គលេខាធិការ នៃអគ្គយកដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅសាលាខេត្តកែប។
  - ធ្វើគ្រូឧទ្ទេសនិងសម្របសម្រួលដល់សិក្ខាកាម មកពីស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ក្រោមអធិបតីភាព លោកជំទាវ អគ្គលេខាធិការ គ.ជ.បជ និងលោក **ណៃ ឈួន** ប្រធានអង្គការ អេស៊ានអាក់ ប្រចាំប្រទេសកម្ពុជា មានអ្នកចូលរួមចំនួន ៦៨នាក់។

- កិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំជាមួយភាគីថៃ លើការអនុវត្ត SOPs ស្តីពីការពិនិត្យការពិភាក្សាលើទម្រង់គ្រប់គ្រងករណី និងឧបសម្ព័ន្ធក្នុងការអនុវត្តនីតិវិធីប្រតិបទដ្ឋាន ស្តីពីការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក្រោមអធិបតីភាព ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។
- សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការប្រតិបត្តិមណ្ឌលស្នាក់នៅ ការគាំទ្រ ការចែករំលែកចំណេះដឹង និងបទពិសោធន៍ ក្នុងចំណោមអ្នកអនុវត្ត ក្រោមអធិបតិភាព លោកជំទាវ **ហ៊ូ និរមិត្តា** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី នៅសណ្ឋាគារពេជ្រដា ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី ។
- សិក្ខាសាលាចែករំលែក ផ្សព្វផ្សាយលទ្ធផលវាយតម្លៃការអនុវត្តគម្រោង ការការពារ និងសិទ្ធិកុមារនៅកម្ពុជា ដោយមានកិច្ចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយនឹងអង្គការតំណក់ទឹក និងអង្គការការីតាសស្វីស និងEU នៅសណ្ឋាគារពូលូវ៉េ រាជធានីភ្នំពេញ។
- កិច្ចប្រជុំក្រុមការងារបច្ចេកទេសជាមួយភាគីថៃ ស្តីពីការពិនិត្យការពិភាក្សាលើទម្រង់គ្រប់គ្រងករណី និងឧបសម្ព័ន្ធ ក្នុងការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ(SOPS) រវាង កម្ពុជា-ថៃ តាមប្រព័ន្ធZOOM ក្រោមអធិបតីភាព ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សណ្ឋាគារសោម៉ាទេវីអង្គរ ខេត្តសៀមរាប ។
- ជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តឧត្តរមានជ័យ។

- លោកប្រធានក្រុមជំនួយកិច្ចការពារជនរងគ្រោះ បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការសង្កេតអត្តសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្ត ទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស រៀបចំដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) ក្រោមអធិបតីភាព លោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ នៅសណ្ឋាគារសោម៉ាទេវីអង្គរ ខេត្តសៀមរាប។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**

- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ បានអញ្ជើញចូលរួម៖
  - កិច្ចប្រជុំជាមួយក្រុមការងារបច្ចេកទេសរបស់ SOMTC ក្រសួងមហាផ្ទៃតាមប្រព័ន្ធអនឡាញ សរុបចំនួន៣៣នាក់ ដើម្បីត្រៀមរៀបចំការងារ ចូលរួមសិក្ខាសាលាជាមួយក្រុមការងារ SOMTC ហ្វីលីពីន ស្តីពីការបង្កើតប្រព័ន្ធទំនាក់ទំនងសម្រាប់មន្ត្រីបង្គោលតំណាងថ្នាក់ជាតិ ACTIP។
  - ពិនិត្យកែតម្រូវ និងរៀបចំឃ្លោងឃ្លា អនុស្សរណៈនៃការយោគយល់គ្នា រវាង គ.ជ.ប.ជ ជាមួយអង្គការមូលនិធិហាការអន្តរជាតិ ស្តីពីការលើក កម្ពស់វិស័យសេដ្ឋកិច្ច សម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ អំពើហិង្សាធ្ងន់ធ្ងរផ្អែកលើយេនឌ័រ និងពលករចំណាកស្រុក ដែលបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ ក្រោមអធិបតីភាពលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។

- កិច្ចប្រជុំក្រុមគ្រូបង្គោលរបស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ដើម្បីបែងចែកមេរៀនស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដើម្បីត្រៀមបើកវគ្គបណ្តុះបណ្តាលនៅតាមបណ្តាខេត្តគោលដៅ ជាពិសេសក្នុងស្រុកចំនួន២ នៅខេត្តបាត់ដំបង។
- ពិនិត្យពិភាក្សា ខ្លឹមសារមេរៀនកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំគ.ជ.ប.ជ។
- ពិនិត្យពិភាក្សា និងផ្តល់យោបល់លើកម្រងសំណួរយល់ដឹងមុនវគ្គ និងក្រោយវគ្គ(Pre-test និង Post-test) សម្រាប់សិក្ខាកាម នៅខេត្តបាត់ដំបង ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។
- កិច្ចប្រជុំលើកទី២ របស់ក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ ដើម្បីស្វែងយល់ពីគោលបំណងធំៗចំនួន៦ ពាក់ព័ន្ធដល់វឌ្ឍនភាពនៃការអនុវត្តអនុសញ្ញាអាស៊ាន ប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ(ACTIP) សហការរៀបចំដោយ ក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា និងដឹកនាំ សម្របសម្រួលដោយ ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងជាប្រធានក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។
- កិច្ចប្រជុំគ្រូបង្គោល ស្តីពីលទ្ធផលនៃការវាយតម្លៃ និងផ្តល់ពិន្ទុដល់សិក្ខាកាម ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងការកែលម្អចំណុចខ្វះខាតក្នុងវិធីសាស្ត្របង្រៀនរបស់គ្រូបង្គោលមួយចំនួន ដើម្បីត្រៀមអនុវត្តការបណ្តុះបណ្តាល នេះតាមបណ្តាខេត្តដទៃឱ្យបានល្អនៅពេលក្រោយ។
- កិច្ចប្រជុំគ្រូបង្គោល ដើម្បីទទួលលទ្ធផលនៃការប្រើប្រាស់ទម្រង់សម្ភាសន៍(ទម្រង់វែង និងទម្រង់ខ្លី) ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស របស់សិក្ខាកាមនៅក្នុងស្រុកចំនួន២នៃខេត្តសៀមរាប គឺស្រុកពួក និងស្រុកស្រីស្នំ ដែលបានទទួលការបណ្តុះបណ្តាលរួច។
- កិច្ចប្រជុំពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូនៅចុងឆ្នាំ២០២១ ស្តីពីសកម្មភាពនៃកិច្ចសហប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា របស់កម្មវិធីអាស៊ាន-អូស្រ្តាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT) ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការដៃ ក្រោមអធិបតីភាពឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេសនៃកម្មវិធី ASEAN-ACT និងលោកជំទាវនាយឧត្តមសេនីយ៍ **យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ។
- កិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ស្តីពីកិច្ចប្រជុំត្រៀមពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីពិនិត្យលទ្ធផលបឋម នៃការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្ត្រជាតិ០៥ឆ្នាំ(២០១៩-២០២៣) ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ និងលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។
- សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការបង្ហាញរបកគំហើញសំខាន់ៗ នៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ក្រោមអធិបតីភាព ឯកឧត្តម **ប៉ែន ពេជ្រសាលី** អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ។

| | |
|---|---|
| | ○ ជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តឧត្តរមានជ័យ។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ ឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>○ សហការៀបចំ និងចូលរួមកម្មវិធីផ្សព្វផ្សាយស្តីពី៖ "**ក្រមសីលធម៌មន្ត្រី នៅមណ្ឌលចត្តាឡីស័ក និងសេវាគាំទ្រ**" តាមប្រព័ន្ធអនឡាញ (ក្រុមទី៣) ដោយមានកិច្ចសហការពីក្រសួងសុខាភិបាល និងទទួលបានការគាំទ្រពីអង្គការយូនីសេហ្វ កម្មវិធីផ្សព្វផ្សាយនេះមានការចូលរួមសរុបប្រមាណ២០០នាក់។<br>○ សហការៀបចំ និងចូលរួមកម្មវិធីផ្សព្វផ្សាយស្តីពី៖ "**ក្រមសីលធម៌មន្ត្រី នៅមណ្ឌលចត្តាឡីស័ក និងសេវាគាំទ្រ**" តាមប្រព័ន្ធអនឡាញ តាមប្រព័ន្ធអនឡាញ (ក្រុមទី៣) ដោយមានកិច្ចសហការពីក្រសួងសុខាភិបាល និងទទួលបានការគាំទ្រពីអង្គការយូនីសេហ្វ កម្មវិធីផ្សព្វផ្សាយនេះមានការចូលរួមសរុបប្រមាណ៣១៤នាក់។<br>○ កិច្ចប្រជុំ ពិនិត្យឡើងវិញការអនុវត្តផែនការបូហូល លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០១៧-២០២០ តាមប្រព័ន្ធវីដេអូអនឡាញ ដែលមានរយៈពេលចំនួនពីរថ្ងៃ រៀបចំដោយលេខាធិការដ្ឋានអាស៊ាន និងអង្គការអាស៊ានអាក់ សមាសភាពមកពីសមាជិកអាស៊ានទាំង១០ អ្នកចូលរួមមានចំនួន១៣០នាក់។<br>○ សិក្ខាសាលា ស្តីពីការបង្កើតប្រព័ន្ធទំនាក់ទំនង សម្រាប់មន្ត្រីបង្គោលតំណាងថ្នាក់ជាតិ ACTIP តាមប្រព័ន្ធអនឡាញ ដែលមានរយៈពេលពីរថ្ងៃ អ្នកចូលរួមសរុបចំនួន៤៣នាក់។<br>○ សិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហការឆ្លងកាត់ព្រំដែនក្នុងចំណោមអ្នកផ្តល់សេវាកម្មនៅម៉ាឡេស៊ី និងកម្ពុជាសម្រាប់ការផ្តល់សេវាកម្មឆ្លើយតបយេនឌ័រ និងការបញ្ជូនបន្តសម្រាប់ស្ត្រីចំណាកស្រុក តាមរយៈអនឡាញ។<br>○ ចុះធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ នៅមណ្ឌលចត្តាឡីស័ក ដែលធ្វើឡើងនៅក្នុងខេត្តចំនួន៥គឺ៖ ខេត្តតាកែវ ខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ ដើម្បីរៀបចំវគ្គស្តីពី ក្រមសីលធម៌មន្ត្រីនៅតាមមណ្ឌលចត្តាឡីស័ក និងសេវាគាំទ្រ។<br>○ ចុះធ្វើបទសម្ភាស សម្រាប់មណ្ឌលចត្តាឡីស័កក្នុងខេត្តចំនួន៧ មានដូចជា ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន សៀមរាប និងខេត្តកំពង់ធំ។ ក្នុងនោះក្រុមការងារបានចុះពិនិត្យមណ្ឌលចំនួន ៥គឺ មណ្ឌលសំពៅលូន មណ្ឌលប៉ៃលិន មណ្ឌលកូបធំ មណ្ឌលកងវ៉ា និងមណ្ឌលសៀបរាប។<br>○ ចុះធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ពីបញ្ហាប្រឈម ដំណោះស្រាយ ក៏ដូចជាសំណូមពរ និងផ្តល់ឯកសារមួយចំនួន នៅមណ្ឌលចត្តាឡីស័ក សម្រាប់ខេត្តដែលមិនទាន់ទទួលបាន និងធ្វើការវាយតម្លៃការអនុវត្តនូវក្រមសីលធម៌របស់មន្ត្រីដែលបានចែងនៅក្នុងវគ្គផ្សព្វផ្សាយ សម្រាប់មណ្ឌលចត្តាឡីស័កនីមួយៗ នៅខេត្តព្រៃវែង ត្បូងឃ្មុំ និងខេត្តកំពង់ចាម។ |

| | |
|---|---|
| | ○ សិក្ខាសាលាស្តីពី ការអនុវត្តន៍គោលការណ៍មិនដាក់ទណ្ឌកម្មសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្នុងរដ្ឋដែលជាសមាជិកអាស៊ាន រៀបចំដោយ ASEAN ACT តាមប្រព័ន្ធអនឡាញ។<br>○ សិក្ខាសាលាចែករំលែក ផ្សព្វផ្សាយលទ្ធផលវាយតម្លៃការអនុវត្តគម្រោង ការការពារ និងសិទ្ធិកុមារនៅកម្ពុជា ដោយមានកិច្ចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយនឹងអង្គការតំណក់ទឹក និងអង្គការកេរីតាសស្វីស និងEU នៅសណ្ឋាគារពូលូវ៉េ រាជធានីភ្នំពេញ។<br>○ សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការបង្ហាញរបកគំហើញសំខាន់ៗ នៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ក្រោមអធិបតីភាព ឯកឧត្តម ប៉ែន ពេជ្រសាលី អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធាន ក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ។<br>○ ជាឧទ្ទេស និងបិទវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តឧត្តរមានជ័យ។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>○ សិក្ខាសាលា ស្តីពីការបង្កើតប្រព័ន្ធទំនាក់ទំនង សម្រាប់មន្ត្រីបង្គោលតំណាងថ្នាក់ជាតិ ACTIP តាមប្រព័ន្ធអនឡាញ ដែលមានរយៈពេលពីរថ្ងៃ។<br>○ កិច្ចប្រជុំលើកទី២ របស់ក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ ដើម្បីស្វែងយល់ពីគោលបំណងធំៗចំនួន៦ ពាក់ព័ន្ធដល់វឌ្ឍនភាពនៃការអនុវត្តអនុសញ្ញាអាស៊ាន ប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ(ACTIP) សហការរៀបចំដោយ ក្រសួងយុត្តិធម៌ និងកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា និងដឹកនាំសម្របសម្រួលដោយ ឯកឧត្តម ប៉ែន ពេជ្រសាលី អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងជាប្រធានក្រុមការងារបច្ចេកទេស នៃកម្មវិធីអាស៊ាន-អូស្ត្រាលី ដើម្បីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។ មានអ្នកចូលរួមចំនួន៣៤នាក់។<br>○ កិច្ចប្រជុំពិនិត្យឡើងវិញ និងឆ្លុះបញ្ចាំងជាមួយដៃគូនៅចុងឆ្នាំ២០២១ ក្រោមអធិបតីភាពលោកជំទាវ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ និងជាអនុប្រធានក្រុមការងារបច្ចេកទេសកម្មវិធី ASEAN ACT ជាមួយក្រុមការងារបច្ចេកទេសកម្មវិធី ASEAN ACT ជាច្រើនរូបទៀត តាមប្រព័ន្ធអនឡាញ។<br>○ សិក្ខាសាលាថ្នាក់ជាតិ ស្តីពី ការបង្ហាញរបកគំហើញសំខាន់ៗ នៃការសិក្សាស្រាវជ្រាវពាក់ព័ន្ធកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប ក្រោមអធិបតីភាព ឯកឧត្តម ប៉ែន ពេជ្រសាលី អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជាប្រធាន ក្រុមការងារបច្ចេកទេសនៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា តាមប្រព័ន្ធអនឡាញ។ |
| ក្រសួងសង្គមកិច្ច | - បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ រយៈពេល ១០ខែ ឆ្នាំ២០២១ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។ |

| | |
|---|---|
| អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានចូលរួមសិក្ខាសាលា ស្តីពីការលើកកម្ពស់គោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩ និងផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ០១លើក។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៣៤លើក អ្នកចូលរួមសរុបចំនួន ៣.៣៦០នាក់ (ស្រី ១.៥៦៦នាក់)** | |
| ខេត្តកណ្តាល | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមៈ<br>○ បើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែតុលា និងលើកទិសដៅអនុវត្តឆ្នាំ២០២១ ចំនួន០១លើក អ្នកចូលរួមចំនួន២៥នាក់ ស្រី១៨នាក់។<br>○ វគ្គបណ្តុះបណ្តាលស្តីពី "ក្រមសីលធម៌របស់មន្ត្រី និងអ្នកពាក់ព័ន្ធនៅក្នុងមណ្ឌលចត្តាលីស័ក" តាមប្រព័ន្ធអនឡាញ ក្រោមអធិបីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ គ.ជ.ប.ជ។<br>○ កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពបើកដ៏ខ្ពង់ខ្ពស់ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងបិទដោយលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៃប្រទេសកម្ពុជា។<br>○ ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែវិច្ឆិកា និងលើកទិសដៅអនុវត្តឆ្នាំ២០២១ ចំនួន០១លើក អ្នកចូលរួម ២៦នាក់ ស្រី ១៩នាក់។<br>○ កិច្ចប្រជុំឆ្លងរបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល ១០ខែ របស់ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>○ ជាមួយក្រុមការងារថ្នាក់ខេត្ត ចុះសួរសុខទុក្ខ និងចែកអំណោយដល់ពលករចំណាកស្រុកមកពីក្រៅប្រទេស ចំនួន ១១លើក ស្មើនឹង ១១ក្រុង/ស្រុក ក្នុងខេត្តកណ្តាល មានចូលរួមសរុប ៥២៩នាក់ ស្រី២៦៩នាក់។<br>○ ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២ ចំនួន០១លើក អ្នកចូលរួម ៦៤នាក់/ស្រី២៩នាក់។<br>○ ជាមួយក្រុមការងារថ្នាក់ខេត្តចំនួន ១៥រូប បានជួបប្រជុំការងារជាមួយឯកអគ្គរាជទូតប្រទេសជប៉ុនប្រចាំកម្ពុជា ដើម្បីស្វែងយល់ពីសកម្មភាពការងារកិច្ចការពារកុមារ នៅសាលប្រជុំសាលាខេត្ត អគារ(A)។<br>- ក្រុមការងារក្រុង ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន១៤លើក អ្នកចូលរួមចំនួន៤៦៨នាក់ ស្រី២១៥នាក់។<br>- លោកស្រីឧត្តមសេនីយ៍ត្រី **ឈឹម វណ្ណនី** ស្នងការរងនគរបាលខេត្ត និងជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមក្នុងសិក្ខាសាលាស្តីពីការគាំទ្រដល់កុមាររងគ្រោះ និងបច្ចេកទេសក្នុងការធ្វើការជាមួយកុមារក្នុងនីតិវិធីព្រហ្មទណ្ឌ និងប្រជុំស្តីពីការត្រួតពិនិត្យការងារសម្អាតប្រាក់ និងពង្រឹងកិច្ចសហការស៊ើបអង្កេតស្រាវជ្រាវផលនៃបទល្មើសសម្អាត់ប្រាក់ដែលបានមកពីបទល្មើសជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងទម្រង់ផ្សេងៗទៀតនៃបទល្មើសជួញដូរមនុស្សតាមប្រព័ន្ធអនឡាញ។ |

| | |
|---|---|
| | - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធសាស្ត្រទាំង៧(INSPIRE) ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហឹង្សាលើកុមារ តាមប្រព័ន្ធអនឡាញ ០១លើក អ្នកចូលរួម ៥០នាក់។ |
| ខេត្តបាត់ដំបង | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមវេទិកាអាស៊ី-អឺរ៉ុបលើកទី១៣ តាមប្រព័ន្ធអនឡាញ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ<br>○ ចូលរួមសិក្ខាសាលា "សិទ្ធិកុមារ និងច្បាប់នានាពាក់ព័ន្ធនឹងកិច្ចការកុមារចំណាកស្រុក" រៀបចំដោយអង្គការហាហ្គា នៅមណ្ឌលទទួលពលករកំរៀង ០១លើក។<br>○ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី បែបបទ និងនីតិវិធីស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រម ០១លើក។<br>○ ចូលរួមកិច្ចប្រជុំស្តាប់អនុសាសន៍ណែនាំពាក់ព័ន្ធនឹងការងារសម្ពោធមណ្ឌលទទួលពលករកំរៀង តាមប្រព័ន្ធអនឡាញ ០១លើក។<br>○ ចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល ១០ខែ របស់ គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។<br>○ សហការរៀបចំពិធីសម្ពោធមណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅមណ្ឌលទទួលពលករកំរៀង ស្រុកកំរៀង។<br>○ រៀបចំកិច្ចប្រជុំពិភាក្សាការងារសម្ពោធមណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តាមប្រព័ន្ធ Zoom។<br>○ ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារកម្ពុជា តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសម្លេង Video Zoom។<br>○ ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងរៀបចំផែនការអនុវត្តបន្តរបស់ក្រុមការងារកិច្ចការពារកុមារខេត្ត តាមប្រព័ន្ធ Zoom។<br>- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួម៖<br>○ ផ្សព្វផ្សាយការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដែលរៀបចំដោយអង្គការការីតាសកម្ពុជា ០១លើក អ្នកចូលរួម ៥៨នាក់(ស្រី)។<br>○ ផ្សព្វផ្សាយ ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ការបញ្ជូន និងគាំទ្រផ្នែកច្បាប់ដល់ពលករក្នុង និងក្រៅស្រុក ដែលរៀបចំដោយអង្គការបន្ទាយស្រី ០១លើក អ្នកចូលរួម ២០នាក់ ស្រី១១នាក់ នៅស្រុកថ្មគោល។<br>○ បានចូលរួមសិក្ខាសាលាស្តីពី "**ការអនុវត្តការងារគាំពារ និងអភិវឌ្ឍកុមារតូចថ្នាក់ក្រោមជាតិ**" តាមប្រព័ន្ធអនឡាញ។<br>○ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី "**ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងដំណើរការធ្វើសមាហរណកម្មជនរងគ្រោះ**"។ |
| ខេត្តសៀមរាប | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ<br>○ បានចូលរួមវគ្គបណ្តុះបណ្តាល បទដ្ឋានអប្បបរមា ស្តីពីការផ្តល់សេវាសំខាន់ៗ ការផ្តល់ប្រឹក្សាមូលដ្ឋាន ការគ្រប់គ្រងករណី និងការបញ្ជូល ចំនួន០១លើក។<br>○ បានចូលរួមវេទិកាអាស៊ី-អឺរ៉ុប ស្តីពី "**ស្ត្រី សន្តិភាព សន្តិសុខ**" តាមប្រព័ន្ធអនឡាញ នៅសាលាខេត្តសៀមរាប។<br>- បានរៀបចំកិច្ចប្រជុំប្រចាំខែតុលា និងត្រីមាសទី៣ ចំនួន០៣លើក អ្នកចូលរួមចំនួន១០៥នាក់ ស្រី៦២នាក់។ |

| | |
|---|---|
| | - មន្ទីរកិច្ចការនារីខេត្ត បានសហការជាមួយរដ្ឋបាលសាលាខេត្ត ក្រសួងកិច្ចការនារី និងអង្គការ UN WOMEN បើកកិច្ចប្រជុំផ្សព្វផ្សាយសមាសភាពក្រុមការងារឆ្លើយតបជាពហុវិស័យ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ តាមរយៈកម្មវិធី ZOOM អ្នកចូលរួមចំនួន៧៣នាក់ ស្រី៥០នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែវិច្ឆិកា ០១លើក អ្នកចូលរួម ៧៤នាក់ ស្រី៣២នាក់។<br>- រដ្ឋបាលស្រុកស្វាយលើ និងស្រុកសូទ្រនិគម រៀបចំកិច្ចប្រជុំប្រចាំខែវិច្ឆិកា ០២លើក អ្នកចូលរួម ៤៥នាក់ ស្រី១២នាក់។<br>- រដ្ឋបាលស្រុកពួកៈ បានចូលរួមបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី ការលើកកម្ពស់និងការការពារសិទ្ធការងារសម្រាប់ពលករ ចំណាកស្រុកកម្ពុជាដែលមានជំនាញទាប នៅប្រទេសថៃ បានចំនួន ០១លើក ។<br>- មន្ទីរអប់រំយុវជន និងកីឡាខេត្ត បានរៀបចំកម្មវិធីជជែកដេញដោលថ្នាក់ខេត្តវគ្គផ្តាច់ព្រ័ត្រ លើប្រធានបទស្តីពី ការរីករាលដាលជំងឺកូវីដ-១៩ ជាកត្តាជំរុញឱ្យមានការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ មានបេក្ខជនសរុប ១០នាក់ ស្រី០៧នាក់ នឹងប្រកួតប្រជែងជម្រុះជុំទី១ លើប្រធានបទ យុវជន គឺជាកត្តាចម្បងក្នុងការទប់ស្កាត់ការកេងប្រវ័ញ្ចកុមារ តាមប្រព័ន្ធអនឡាញ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០២១ ០១លើក អ្នកចូលរួម ៤៦នាក់ ស្រី២៧នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចពិភាក្សាលើការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២១ ជាមួយមន្ទីរ អង្គភាព និងអង្គការដៃគូជាតិ អនត្តជាតិ បានចំនួន ០២លើក ដែលមានចំនួនចូលរួមសរុប ៧៥នាក់/ស្រី៣២នាក់។<br>- រដ្ឋបាលស្រុកសូទ្រនិគម រៀបចំកិច្ចប្រជុំប្រចាំខែធ្នូ ០១លើក អ្នកចូលរួម ៣៣នាក់ ស្រី១៤នាក់។ |
| ខេត្តកំពង់ចាម | - បានប្រជុំផ្សព្វផ្សាយ ដល់ថ្នាក់ខេត្ត ក្រុង ស្រុក ចំនួន១២លើក អ្នកចូលរួមចំនួន៤៥៨នាក់ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- បានប្រជុំផ្សព្វផ្សាយ ដល់ថ្នាក់ខេត្ត ក្រុង ស្រុក ចំនួន១៥លើក អ្នកចូលរួមចំនួន៥៥៣នាក់ ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- បានចូលរួមធ្វើបទបង្ហាញ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាព ០១លើក តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួមប្រមាណ ១៥នាក់។<br>- បានចូលរួមធ្វើបទបង្ហាញ ស្តីពី "លទ្ធផលការងារទេសន្តប្រវេសន៍ និងការគៀគរធនធានជួយដល់ពលករ ព្រមទាំងការគ្រប់គ្រងករណី និងការផ្តល់សេវាដល់ជនរងគ្រោះ" ចំនួន០២លើក ដែលរៀបចំដោយអង្គការភ្នំស្រី និង LSCW។<br>- បានចូលរួមធ្វើបទបង្ហាញ ស្តីពីចំណាកស្រុកប្រកបដោយសុវត្ថិភាពក្នុងកិច្ចប្រជុំ និងវេទិកាសហគមន៍ ០២លើក នៅស្រុកចំការលើ និងស្រុកស្ទឹងត្រង់ មានអ្នកចូលរួមប្រមាណ ១០៤នាក់។ |
| ខេត្តត្បូងឃ្មុំ | - លេខាធិការដ្ឋានគជ.ប.ខ. ខេត្ត សហការជាមួយរដ្ឋបាលខេត្ត រៀបចំពិធីប្រកាសសមាសភាពគណៈកម្មាធិការខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផ្សព្វផ្សាយស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជាម ច័ន្ទសោភ័ណ** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួមចំនួន ៤២នាក់។ |

| | |
|---|---|
| **ខេត្តឧត្តរមានជ័យ** | - បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារចំនួន០១លើក អ្នកចូលរួមចំនួន១៨នាក់ ស្រី០៣នាក់។<br>- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារចំនួន ០១លើក អ្នកចូលរួមចំនួន២០នាក់ ស្រី១៧នាក់។<br>- ក្រុមការ គ.ខ.ប.ជ បានចុះពិនិត្យមើលស្ថានភាពប្រជាពលករ បានត្រលប់មកពីប្រទេសថៃមកកម្ពុជាវិញតាមច្រកអន្តរជាតិអូរស្មាច់ ០៦លើក មានពលករសរុប ៩៣៦នាក់ ស្រី៤២០នាក់។<br>- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ០២វគ្គ រៀបចំដោយរដ្ឋបាលខេត្ត មានសិក្ខាកាមចូលរួមសរុប ៨២នាក់/ស្រី៣៣នាក់។ |
| **ខេត្តមណ្ឌលគីរី** | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមវេទិកាអាស៊ី-អឺរ៉ុបលើកទី១៣ តាមប្រព័ន្ធអនឡាញ។ |
| **ខេត្តកំពង់ឆ្នាំង** | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំប្រចាំខែតុលា និងខែវិច្ឆិកា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ចំនួន ០២លើក។<br>- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ចំនួន០១លើក អ្នកចូលរួមចំនួន១៦នាក់ ស្រី១៥នាក់។<br>- ស្រុកទឹកផុស<br>○ គ.ក.ស.ក បានប្រជុំផ្សព្វផ្សាយប្រចាំខែតុលា លើខ្លឹមសារការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន០១លើក អ្នកចូលរួមចំនួន២៦នាក់ ស្រី១៣នាក។<br>○ សមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ បានប្រជុំផ្សព្វផ្សាយប្រចាំខែតុលា លើខ្លឹមសារការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ចំនួន ០១លើក អ្នកចូលរួម២១នាក់(ស្រី)។<br>○ បានប្រជុំផ្សព្វផ្សាយដល់គណៈបញ្ជាការឯកភាពរដ្ឋបាលស្រុក លើខ្លឹមសារការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន០១លើក អ្នកចូលរួមចំនួន៤១នាក់ ស្រី១២នាក់ តាមប្រព័ន្ធអនឡាញ។<br>○ បានប្រជុំផ្សព្វផ្សាយដល់នាយប៉ុស្តិ៍រដ្ឋបាលឃុំ លើខ្លឹមសារការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន០១លើក អ្នកចូលរួមចំនួន១៨នាក់ ស្រី០៣នាក់។<br>- ស្រុកបរិបូណ៌គ.ក.ស.ក បានប្រជុំផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុក ចំនួន០២លើក អ្នកចូលរួមចំនួន៥០នាក់ ស្រី៣២នាក់។<br>- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ០២លើក អ្នកចូលរួមចំនួន៣៤នាក់ ស្រី២៨នាក់។<br>- លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំប្រចាំខែធ្នូ ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ០១លើក។<br>- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ០២លើក អ្នកចូលរួមចំនួន ៣៧នាក់ ស្រី៣៣នាក់។ |
| **ខេត្តកែប** | - លោកជំទាវ អ៊ុល ភីរុណ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ស្តីពី លទ្ធផលការងារ រយៈពេល ១០ខែ ឆ្នាំ២០២១ និងដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តបន្តចំនួន ០១លើក។ |

| | |
|---|---|
| | - នាយ នាយរង និងមន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចំនួន ០៥នាក់ ស្រី០៤នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការគាំទ្រកុមាររងគ្រោះ និងបច្ចេកទេសក្នុងការធ្វើការជាមួយកុមារក្នុងនីតិវិធីព្រហ្មទណ្ឌ តាមប្រព័ន្ធអនឡាញ។<br>- មន្ត្រីការិយល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចំនួន ០៣នាក់ ស្រី០២នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការឆ្លើយតប និងបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធើណែត នៅស្នងការដ្ឋាននគរបាលខេតត្តកែប ។ |
| **ខេត្តកោះកុង** | - បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី «ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស ដល់មន្ត្រីជំនាញ» តាមប្រព័ន្ធZOOM។<br>- លោក **សុវណ្ណ** ប៊ុនធឿន ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីសុខភាពជនទេសន្តប្រវេសន៍ ២០២១-២០៣០ នៅសណ្ឋាគារអង្គរប៉ារ៉ាដាយ( Angkor Paradise ) ខេត្តសៀមរាប ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ |
| **ខេត្តកំពត** | - បានចូលរួមវគ្គបណ្តុះបណ្តាល ការមិនបង្កការឈឺចាប់បន្ថែម និងការគ្រប់គ្រងករណី ពលករចំណាកស្រុក។<br>- មន្ត្រីនគរបាល ០៣រូប បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ស្តីពីការគាំទ្រកុមាររងគ្រោះ និងបច្ចេកទេស ក្នុងការធ្វើការជាមួយកុមារក្នុងនីតិវិធិព្រហ្មទណ្ឌ តាមប្រព័ន្ធ Zoom។ |
| **ខេត្តព្រៃវែង** | - លោកស្រី **លៀង** **ស្រីម៉ុល** អភិបាលរង និងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ ខេត្ត បានដឹកនាំប្រតិភូខេត្ត ចូលរួមកិច្ចប្រជុំពិភាក្សាការងារស្តីពី ការចុះប្រម៉ាណតម្រូវការផ្នែកសុខភាពទេសន្តប្រវេសន៍កម្ពុជា មកពីប្រទេសវៀតណាម ក្នុងបរិបទកូវីដ-១៩ នៅច្រកព្រំដែនអន្តរជាតិម៉ឺនជ័យ ០១លើក ដឹកនាំដោយលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ អ្នកចូលរួមចំនួន២៦នាក់ ស្រី០៧នាក់។<br>- បានចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ ១០ខែ ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។<br>- លេខាធិការដ្ឋានគ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែធ្នូ ០១លើក អ្នកចូលរួមចំនួន២៨នាក់ ស្រី២០នាក់។<br>- លោកស្រី **លៀង** **ស្រីម៉ុល** អភិបាលរង និងជាប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ ខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការចំណាកស្រុកដោយប្រថុយប្រថាន ០១លើក រៀបចំដោយក្រសួងកិច្ចការនារី នៅសាលាខេត្តព្រៃវែង មានអ្នកចូលរួម ៤២នាក់ ស្រី៣២នាក់។<br>- ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការស៊ើបអង្កេតបទល្មើសជួញដូរ និងអាជីវកម្មផ្លូវភេទ រៀបចំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងអង្គការសម្ព័ន្ធចាប់ដៃ ០១លើក តាមប្រព័ន្ធអនឡាញ អ្នកចូលរួម០៦នាក់ ស្រី០២នាក់។ |
| **ខេត្តស្វាយរៀង** | - ក្រុមការងារនៃគ.ខ.ប.ជ ខេត្តស្វាយរៀង ដឹកនាំដោយ លោកជំទាវ ឯក **សុវណ្ណតារ** អភិបាលរងខេត្ត និងជាអនុប្រធាន គ.ខ.ប.ជ បានអមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ដើម្បីជួបប្រជុំប៉ាន់ប្រមាណតម្រូវការផ្នែកសុខភាពជនទេសន្តប្រវេសន៍កម្ពុជាមកពីប្រទេសវៀតណាម និងការគ្រប់គ្រង |

| | |
|---|---|
| | វិហ្សរទេសន្តប្រវេសន៍ឆ្លងកាត់ព្រំដែន ក្នុងបរិបទការរាតត្បាតកូវីដ-១៩ នៅតាមច្រកទ្វារព្រំដែនចំនួន ០៤ គឺច្រកទ្វារព្រំដែនដូង ច្រកទ្វារព្រំដែនទ្វេកាគីបុសមន ច្រកទ្វាព្រំដែនអន្តរជាតិបាវិត និងច្រកទ្វារព្រំអន្តរជាតិព្រៃវល្លិ៍។ |
| ខេត្តព្រះវិហារ | - រៀបចំកិច្ចប្រជុំប្រកាសសេចក្តីសំរេចគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខាធិការដ្ឋានខេត្ត ០១លើក អ្នកចូលរួម២៨នាក់ ស្រី១០នាក់។ |
| ខេត្តមណ្ឌលគិរី | - បានចូលកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ១០ខែ ឆ្នាំ២០២១ របស់គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ ០១លើក។ |
| ខេត្តកំពង់ធំ | - លោកស្រីស្នងការរងនគរបាលខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ក្រមសីលធម៌របស់មន្ត្រី និងអ្នកពាក់ព័ន្ធនៅក្នុងមណ្ឌលចត្តាលីស័ក" តាមប្រព័ន្ធអនឡាញ ក្រោមអធិបីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ គ.ជ.ប.ជ។ |
| ខេត្តប៉ៃលិន | - លោកជំទាវអភិបាល នៃគណៈអភិបាលខេត្ត បានចូលរួមវេទិកាអាស៊ី-អឺរ៉ុប ស្តីពី "ស្ត្រី សន្តិភាព សន្តិសុខ" តាមប្រព័ន្ធអនឡាញ។ |
| ខេត្តព្រះសីហនុ | - លេខាធិការដ្ឋាន បានប្រជុំក្រុមការងារថ្នាក់ខេត្ត ថ្នាក់ស្រុក ដល់ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះហិង្សាទាក់ទងនិងយេនឌ័រ ចំនួន០៣លើក អ្នកចូលរួម ចំនួន១២០នាក់ ស្រី៤០នាក់ តាមប្រព័ន្ធអនឡាញ។ |
| ខេត្តតាកែវ | - លោកជំទាវអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ<br>○ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "ក្រមសីលធម៌របស់មន្ត្រី និងអ្នកពាក់ព័ន្ធនៅក្នុងមណ្ឌលចត្តាលីស័ក" តាមប្រព័ន្ធអនឡាញ ក្រោមអធិបីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ គ.ជ.ប.ជ។<br>○ បានចូលរួមវេទិកាអាស៊ី-អឺរ៉ុប ស្តីពី "ស្ត្រី សន្តិភាព សន្តិសុខ" តាមប្រព័ន្ធអនឡាញ។<br>○ វគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ ដើម្បីលប់បំបាត់បានការចំណាកស្រុកខុសច្បាប់។<br>○ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២ របស់ក្រសួងកិច្ចការនារី ដើម្បីអនុវត្តនូវគោលការណ៍គ្រឹះសំខាន់របស់ CEDAW។<br>○ បានចូលរួមប្រជុំបូកសរុបការងារ គ.ក.ស.ក ប្រចាំឆ្នាំ របស់ក្រុងដូនកែវ ០១លើក។<br>○ វគ្គបណ្តុះបណ្តាល ការលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ និងផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ។ |